n:8 - Tosseanea vaddey. R. 611-5-53

# ព្រះរាជអាណាចក្រកម្ពុជា

## មន្ទីរស្តីការក្រសួងសិក្សាធិការ

# ទស្សនាវដ្តី

សម្រាប់

# គ្រូបង្រៀន

ឆ្នាំទី ៤ លេខ ៨

ខែឧសភា ព.ស. ២៤៩៥

ឆ្នាំសិក្សា ១៩៥២-១៩៥៣

# ព្រះរាជាណាចក្រកម្ពុជា

មន្ទីរស្ដីការ ក្រសួងសិក្សាធិការ

## ទស្សនាវដ្ដី សម្រាប់គ្រូបង្រៀន

បញ្ជីរឿង ទំព័រ


| | |
|---|---|
| សេចក្ដីណែនាំ ... ... ... ... ... ... ... ... ... ... ... ... | ៣ |
| ឧត្ដមដ្ឋាន មធ្យមដ្ឋានទី ២ ភាសា ... ... ... ... ... ... ... ... | ៩ |
| មធ្យមដ្ឋានទី ១ ភាសា ... ... ... ... ... ... | ១៦ |
| អាទិកដ្ឋាន ភាសា ... ... ... ... ... ... | ១៩ |
| បរិវច្ឆណដ្ឋាន ភាសា ... ... ... ... ... ... | ៣០ |
| កុមារដ្ឋាន ភាសា ... ... ... ... ... ... | ៣៤ |
| តែងសេចក្ដីសម្រាប់ប្រថមភូមិបំពេញវិឌ្ឍ ... ... ... ... .. | ៣៧ |
| តែងសេចក្ដីសម្រាប់ប្រថបភូមិជាន់ដំបូង ... ... ... ... ... | ៤១ |
| អាទិកដ្ឋាន នព្វន្ត - រង្វាស់ - រង្វាល់ ... ... ... ... ... | ៤៥ |
| បរិវច្ឆណដ្ឋាន នព្វន្ត - រង្វាស់ - រង្វាល់ ... ... ... ... ... | ៥១ |
| កុមារដ្ឋាន នព្វន្ត - រង្វាស់ - រង្វាល់ ... ... ... ... ... | ៥៧ |
| អាទិកដ្ឋាន វត្ថុស្វាធ្យាយន៍ - វិធីបង្ការរោគ ... ... ... ... | ៦០ |
| បរិវច្ឆណដ្ឋាន - វត្ថុស្វាធ្យាយន៍-វិធីបង្ការរោគ ... ... ... ... | ៦៦ |
| កុមារដ្ឋាន វត្ថុស្វាធ្យាយន៍ - វិធីបង្ការរោគ ... ... ... ... | ៧១ |
| លោកនីតិ សម្រាប់គ្រប់ថ្នាក់ ... ... ... ... ... ... | ៧២ |
| មេសូត្រតែមាត់ ... ... ... ... ... ... ... ... ... ... | ៧៨ |

# សេចក្ដីណែនាំ

## អំពីបង្រៀនតែងសេចក្ដី

ការតែងសេចក្ដីជាវិជ្ជាសំខាន់បំផុត ពីព្រោះជាការនាំឲ្យកូនសិស្ស មានប្រាជ្ញាស្មារតីវៃវៀង នាំឲ្យចេះនិយាយហើយសរសេរត្រឹមត្រូវផង ចូលប្រឡងក៏នឹងមានសេចក្ដីសរសើរ លុះធំឡើងនឹងធ្វើកងរាជការឬនឹងរកស៊ីអ្វីក៏មិនគាប់ចិន ដូច្នេះសូមលោកគ្រូបង្រៀនកូនសិស្សឲ្យចេះតែងសេចក្ដីបានត្រឹមត្រូវ ការបង្រៀនកូនសិស្សតែងសេចក្ដីនេះមិនចាំតែដល់កូនសិស្សចេះមើលចេះសរសេរមែនទែនហើយទើបបង្រៀនបាននោះទេ ត្រូវបង្រៀនតាំងពីដំបូង គឺចោទសួរជាសេចក្ដីងាយ ៗ ឲ្យឆ្លើយតាមសេចក្ដីដែលបានបង្រៀនហើយឬឲ្យបំពេញឃ្លាដែលលោកគ្រូទុកចំហពាក្យខ្លះឲ្យបន្ថែមឬឲ្យយកពាក្យមួយម៉ាត់ៗ មកធ្វើជាឃ្លាៗឬយកគំនូររូបវត្ថុអ្វីមកបង្ហាញនាំឲ្យអធិប្បាយបែបងាយ ៗ ហើយឲ្យកូនសិស្សតែងសេចក្ដីពីគំនូររូបនោះតាមបានឃើញបានដឹងបានឮ ឬនាំអធិប្បាយអំពីសត្វរបស់នឹងមនុស្សណាដែលកូនសិស្សបានស្គាល់ហើយ ។

សូមលោកគ្រូជ្រាបថា ការតែងសេចក្ដីមិនគឺអ្វីក្រៅពីចេះតែងពាក្យជាឃ្លាៗទេ ប៉ុន្តែត្រូវពាក្យឃ្លានោះតែងឲ្យល្អ ហើយឲ្យជាប់គ្នាហូរហែតាមដំណើររឿងផង ដូច្នេះត្រូវបង្រៀនតែងឃ្លានេះឲ្យច្រើន សូមលោក

គ្រូបង្រៀនឲ្យតែងជាឃ្លាពេញបរិបូណ៌ឆ្លើយទឹងពាក្យចោទ  កុំទទួលយកពាក្យឆ្លើយមួយម៉ាត់ៗ ឧបមាដូចពាក្យចោទសួរថាអ្នកស្គាល់វត្តណា? គេឆ្លើយថាវត្តអង្គបក ។ សូមកុំទទួលចម្លើយដូច្នេះត្រូវឲ្យតែងសេចក្តីថា ខ្ញុំបាទបានស្គាល់វត្តអង្គបកនៅក្នុងឃុំត្រពាំងពងស្រុកឈូកខេត្តកំពត ។ ពាក្យចោទថាវត្តនោះយ៉ាងដូចម្តេច ។ គេឆ្លើយថាចាស់ ។ សូមកុំទទួលយកចម្លើយដូច្នេះត្រូវឲ្យឆ្លើយ ថាវត្តនោះ ជាវត្តចាស់បុរាណ សព្វថ្ងៃនេះព្រះវិហារទឹងកុដិលោកបាក់ពុកទ្រុតទ្រោមច្រើនណាស់ហើយ  ប៉ុន្តែឧបាសកទឹងព្រះភិក្ខុសង្ឃកំពុងគិតជួសជុលឲ្យបានល្អឡើងវិញ (ល) ។

ការតែងសេចក្តីមានពីរយ៉ាងគឺ **តែងមាត់ទទេមួយយ៉ាងតែងដោយសរសេរមួយយ៉ាង**  កូនសិស្សណាដែលមិនទាន់ចេះសរសេរមែនទែនត្រូវបង្រៀនឲ្យតែងសេចក្តីតែមាត់ទទេ  ការនេះត្រូវលោកគ្រូចោទសួរហើយឲ្យឆ្លើយ  លោកគ្រូកែតំរូវពាក្យហើយឲ្យថាច្រើនដងច្រើនគ្នាទៅទម្លាប់កូនសិស្សដូច្នេះមានប្រយោជន៍ឲ្យវាចេះតែងសេចក្តីបានល្អកាលណាវាចេះសរសេរឡើងផង លោកគ្រូអធិប្បាយរឿងអ្វីមួយ យ៉ាងខ្លីឲ្យកូនសិស្សស្តាប់  ហើយឲ្យវាអធិប្បាយតាមលោកគ្រូឡើងវិញ  លោកគ្រូត្រូវកែពាក្យវាអធិប្បាយខុស ។

## អំពីរើសសេចក្ដីឲ្យកូនសិស្សតែង

ឯសេចក្ដីឲ្យកូនសិស្សតែងមិនត្រូវយកសេចក្ដីណាដែលកូនសិស្សមិនដែលឃើញ-ដឹង-ឮនោះទេ ត្រូវរើសយកសេចក្ដីតែក្នុងរឿងណាដែលកូនសិស្សបានរៀនរួចហើយ ប៉ុន្តែដាក់ឲ្យផ្លែកគ្នាបន្តិចប្រយោជន៍ឲ្យកូនសិស្សខំគិតធ្វើផង សូមលោកគ្រូចាំថាដំបូងត្រូវធ្វើឲ្យងាយៗ រួចឲ្យពិបាកបន្តិចៗឡើង បើសេចក្ដីនោះពិបាកត្រូវជួយកូនសិស្សគឺ កាលណាបង្ហាត់និយាយរួចហើយ លោកគ្រូមើលសេចក្ដីដែលលោកគ្រូតែងដោយផ្ចិតផ្ចង់នោះឲ្យវាស្ដាប់បាន២ឬ៣ដងៗ

## អំពីផ្លាស់ប្ដូរសេចក្ដីតែង

ត្រូវផ្លាស់ប្ដូរសេចក្ដីតែងជារឿយៗផង នៅកុមារដ្ឋាននឹងបវិច្ចណាដ្ឋាន ម្ដងឲ្យធ្វើឃ្លានឹងពាក្យមួយម៉ាត់ៗ ម្ដងទៀតឲ្យឆ្លើយនឹងពាក្យចោទសួរម្ដងទៀតឲ្យបំពេញឃ្លាដែលលោកគ្រូទុកចំហពាក្យខ្លះបន្ថែមៗ នៅអាទិកដ្ឋានដំបូងឲ្យធ្វើដូចមានអធិប្បាយខាងលើ រួចឲ្យតែងសេចក្ដីតាមគំនូររូបដែលលោកគ្រូយកមកបង្ហាញ រួចឲ្យតែងសេចក្ដីអធិប្បាយអំពីសត្វឬរបស់ឬមនុស្សណាដែលកូនសិស្សបានស្គាល់ហើយ រួចឲ្យអធិប្បាយអំពីបុណ្យអ្វីមួយដែលវាបានទៅមើលហើយ រួចឲ្យតែងសេចក្ដី

សំបុត្រសំនួរ សំបុត្រលក់របស់ សំបុត្របង់ការប្រាក់ សំបុត្រសញ្ញា ផ្សេងៗ (ល) ។

## អំពីរបៀបតែងសេចក្ដីនិងការហាត់ធ្វើមាត់ទទេ

យើងមិនត្រូវសរសេរតែសេចក្ដីបង្ហាប់នៅក្ដារខៀនបញ្ឈរហើយប្រើកូនសិស្សឲ្យធ្វើតាមនោះទេ ធ្វើយ៉ាងនេះកូនសិស្សពុំចេះធ្វើឡើយ ហើយនៅស្ងៀមនឹងខាតប្រយោជន៍ធំ ត្រូវចោទសួរនាំកូនសិស្សនិយាយហើយបង្រៀនឲ្យគេរៀបតែងសេចក្ដីនោះឲ្យបានបរិបូណ៌ កាលណាសួរបានសេចក្ដីហើយត្រូវឲ្យកត់របៀបសេចក្ដីនោះនៅក្ដារខៀនបញ្ឈរទុកជាគំរូឲ្យកូនសិស្សតែងសេចក្ដីតាម ឧបមាដូចនិយាយអំពីវត្តត្រូវកត់របៀបដែលនាំកូនសិស្សគេឃើញដូចមានខាងក្រោមនេះ ។

១- បរិយាយផ្ដើមសេចក្ដី ។ ២ របៀបសេចក្ដីគឺ ក- ទីកន្លែង ខ- ខាងក្រៅវត្ត, គ- ខាងក្នុងវត្ត, ឃ- ព្រះវិហារនិងក្នុងព្រះវិហារ ង- លោកសំឃ, ច- កូនសិស្សលោក, ឆ- ឧបាសកឧបាសិកា ជ- វេលាបុណ្យ, ឈ- សេចក្ដីចំរើន ។

៣- យោបល់យល់ឃើញ ។

សូមលោកគ្រូចាំថាមុននឹងឲ្យកូនសិស្សតែងសេចក្ដីមួយៗដោយ

សរសេរត្រូវបង្ហាត់តែងសេចក្ដីនោះដោយមាត់ទទេឲ្យបានយល់ប្រាកដសិនឯការបង្ហាត់នេះគឺចោទសួរកូនសិស្សតាមសេចក្ដីនោះ ។

## អំពីកែសេចក្ដីកូនសិស្ស

កូនសិស្សតែងសេចក្ដីរួចហើយ មានចំណង់ចង់ឲ្យលោកគ្រូកែសេចក្ដីរបស់ខ្លួនគ្រប់គ្នា លោកគ្រូក៏ត្រូវកែសេចក្ដីរបស់កូនសិស្សជាប្រយោជន៍២ប្រការ ។ ប្រការ ១– ប្រយោជន៍នឹងបានជ្រាបថាកូនសិស្សបានយកចិត្តទុកដាក់តែងសេចក្ដីនោះដោយផ្ចិតផ្ចង់ឬទេ លោកគ្រូត្រូវដាក់ពិន្ទុឲ្យដឹងដម្លៃការរបស់កូនសិស្សម្នាក់ ៗ ។ ប្រការ ២– ប្រយោជន៍នឹងឲ្យកូនសិស្សដឹងថានិយាយដូច្នេះខុស ត្រូវនិយាយដូច្នោះវិញ វានឹងចំណាំមិនធ្វើឲ្យខុសទៅក្រោយទៀត ។ លោកគ្រូត្រូវកែសេចក្ដីកូនសិស្សគ្រប់គ្នាឯផ្ទះក្រៅពេលរៀន បើលោកគ្រូមិនកែសេចក្ដីរបស់កូនសិស្សទេ កូនសិស្សនឹងធ្វេសប្រហែសមិនខំតែងសេចក្ដីយូរទៅវាមិនតាំងតែងសេចក្ដីផងជាការខាតប្រយោជន៍ធំបំផុត លោកគ្រូត្រូវប្រគល់សេចក្ដីតែងឲ្យកូនសិស្សវិញមុននឹងឲ្យតែងសេចក្ដីមួយទៀត សេចក្ដីលោកគ្រូយល់ឃើញដូចម្ដេច ៗពីការកូនសិស្សម្នាក់ ៗ ត្រូវកត់នឹងទឹកខ្មៅក្រហមនៅសេចក្ដីកូនសិស្សនោះ លោកគ្រូត្រូវដាក់សំគាល់យ៉ាងដូចម្ដេចឲ្យដឹងថា: សេចក្ដីនេះនិយាយខុស សេចក្ដីនោះនិយាយដដែល ៗ ពាក្យនោះសរសេរអក្សរខុស ។

## អំពីប្រាប់សេចក្ដីខុសរបស់កូនសិស្ស

វេលាកែសេចក្ដីកូនសិស្សលោកគ្រូត្រូវកត់ចំណាំថា ឈ្មោះនេះនិយាយដូច្នេះជាខុសធំ ឈ្មោះនោះនិយាយដូច្នោះជាខុសធំ ដល់ថ្ងៃប្រគល់សៀវភៅឲ្យកូនសិស្សវិញឬដល់ថ្ងៃឲ្យសេចក្ដីតែង ១ ទៀតត្រូវហៅកូនសិស្សនោះមកសរសេរសេចក្ដីរបស់វានៅក្ដារខៀនបញ្ឈរ ហើយឲ្យកូនសិស្សឯទៀតរិះគន់ រួចលោកគ្រូឲ្យគំរូមួយកែសេចក្ដីនោះឡើងឯពាក្យសរសេរអក្សរខុសក៏ត្រូវធ្វើដូចគ្នា ជាការនាំឲ្យកូនសិស្សចំណាំគ្រប់គ្នាផង ។

ល-ម៉ានិត្យូដ

ស្រង់ពីកិច្ចសិក្សាបឋមវិជ្ជាបារាំងសែសខេមរ ១៩៣៤

គង-ឈុំ

ឧត្តមដ្ឋាន

# ការធ្វេសប្រហែសរបស់មាតាបិតា

ក្មេងតូចៗ ចូលចិត្តស្រវាចាប់យកអ្វីៗដាក់ទៅក្នុងមាត់ បើជាវត្ថុតូចឬទន់ ក៏ល្មមលេបចូលទៅបានដោយស្រួល បើជារបស់រឹងដូចជាលុយសេនឬដុំក្រួសដុំថ្ម ក៏អាចទៅជាប់ណែនក្តន់នៅបំពង់កមិនខាន ។

គ្រឿងស៊ីគ្រឿងផឹករបស់ក្មេងតោងតែប្រយ័ត្ននឹងចាត់ចែងតាមអាយុរបស់ក្មេង ៗ ក្មេងតូច ៗ មិនត្រូវឲ្យស៊ីរបស់រឹង ផ្លែឈើដែលមានគ្រាប់ឡើយ ព្រោះអាចមានអន្តរាយបានដូចមានតួយ៉ាងនិយាយថាមាន កូនចិនម្នាក់អាយុប្រមាណបីឆ្នាំ ម្តាយឪពុកនាំទៅមន្ទីរពេទ្យ និយាយថា វាដកដង្ហើមទាស់ៗ យ៉ាងលំបាកមុខមាត់ឡើងខៀវ ៗ គ្រូពេទ្យសួររឿងរ៉ាវមិនបានសេចក្តីសោះ ក៏សន្និដ្ឋានថាក្រែងវាកើតរោគខាន់ស្លាក់ តែពិនិត្យទៅមិនមានអាការរោគបែបនេះឡើយ ហើយពិចារណាតទៅទៀតឃើញថា វាដកដង្ហើមទាស់ៗចំណែកខាងលើ ទើបព្រមព្រៀងគ្នាថា តោងវះកក្មេងនោះជាប្រញាប់តែបន្តិចទុកយូរទៅទៀតពុំបាន ខណៈដែលវះកនោះក្មេងក៏កណ្តាស់ ស្រាប់តែមានគ្រាប់ទៀបរបូតធ្លាក់មកតាមមុខរបួសមួយគ្រាប់ ហើយក្មេងនោះក៏ដកដង្ហើមបានស្រួលដូចធម្មតា ។ នេះជាតួ-

ដែលមាតាបិតាធ្វេសប្រហែសបណ្ដោយ ឲ្យក្មេងបរិភោគរបស់មិនសមគួរ តាមអាយុ  និងធ្វេសប្រហែសគ្រាតែមិនដឹងថាកូនមានហេតុមិនស្រួល តាំងពីកាលណាចុះស៊ីអ៊ីផង ។

លោក ប. ឈុំ

ពន្យល់ពាក្យ.–

សន្និដ្ឋាន= (ម. ថ. សនទីតឋាន) ន. សេចក្ដីចូលចិត្ត ការយល់ដាក់...

កណ្ដាស់= កិ. ឈ្លក់ខ្យល់ដោយឆ្លួល......

មុខរបួស= មុខដំបៅ (កន្លែងដែលពិការ)

វេរៈ = អន្តរាយ វិនាស ខូច...

សទិសសព្ទ= ទៀប ន. ទៀបជុំ ទៀបសំរិទ្ធ ទេ បកោះ ។

ទាប គ. ដីទាប ផ្ទះទាប

អក្ខរាវិរុទ្ធ= ប្រមាណ (ណ) មន្ទីរ (រ) ពេទ្យ (ទ្យ) សន្និដ្ឋាន (ដ្ឋាន) ពិនិត្យ (ត្យ)

សរុបពាក្យ.– ក្មេងតូចៗចូលចិត្តធ្វើអ្វីកាលណាវាលេង ។ មាតាបិតាត្រូវប្រយ័ត្នដូចម្ដេចខ្លះនឹងបានជៀសវាងសេចក្ដីអន្តរាយដល់កូន ៗ កូនបិនដែលគេមិនទាន់ខេះមានហេតុដូចម្ដេច ។ល។

## ឧត្តមដ្ឋាន

# សេចក្ដីធ្វេសប្រហែសក្នុងការបរភោគ

កុំយល់ថាការស៊ីនិងការផឹកនេះជារបស់ងាយស្រួល ព្រោះជួនកាលអាចឲ្យទោសដល់យើង ដូចជាមនុស្សល្មោភស៊ីច្រើនតែកាយញាត់ស៊ើរ តែចំពោះមិនទាន់ ។ យើងអាចសង្កេតឃើញបានដោយងាយ មនុស្សមែបនេះច្រើនតែអួលបាយសម្ទៀយៗជួនកាលស្លាក់ឆ្អឹងក៏មាន ដូចមានយាយចាស់ម្នាក់ បរិភោគនំបញ្ចុកលេបចូលទៅក្នុងបំពង់ក ព្រមទាំងទឹកសម្ល ដោយឥតទំពា ហើយដឹងខ្លួនថាហាក់ដូចជាមានអ្វីធ្លាក់ទៅក្នុងបំពង់ក ហើយយាយនោះពុំមានធ្មេញផង កាលនាំខ្លួនគាត់ទៅឆ្លុះមើលនៅមន្ទីរពេទ្យស្រាប់តែឃើញមានម្ជុលមួយនៅក្នុងក្រពះអាហារ តែជួនជាគ្រោះល្អដល់ពេលបន្ទោបង់ឧច្ចារៈម្ជុលក៏ជ្រុះចេញទៅ ដោយស្រួល ។

មានតួយ៉ាងមួយទៀតថា ហុតទឹកសម្លដោយទាំងផ្លែសន្ទូចធ្លាក់ចូលទៅក្នុងបំពង់ក នេះមកអំពីការធ្វេសប្រហែសរបស់អ្នកបរិភោគអាហារ ។ មនុស្សចាស់ខ្លះពុំមានធ្មេញទេ តែចូលចិត្តបរិភោគគ្រឿងងឹស្វិត ដូចសាច់គោជាដើម ។ មានតួយ៉ាងជាច្រើន មនុស្សខ្លះគោស្រ័យសាច់ដុំទាំងឥតទំពា ហើយដុំសាច់នៅជាប់ណែនគគ្គក្នុងបំពង់ក លេបបញ្ចូលក៏នៅតែមិនចូល គេនាំខ្លួនទៅមន្ទីរពេទ្យព្យាបាលរោគ ។

លោក ប. ឈុំ

ពាក្យពន្យល់.–

ល្មោភ= គុ. ដែលមានលោភច្រើន ។ ល្មោភស៊ី ស៊ីច្រើន

បន្ទោបង់ទុច្ចារៈ= (ម. ថ. អុច្ចារៈ) បញ្ចេញលាមក (បត់ជើងធំ)

វេវចនៈ បន្ទោបង់= បញ្ចេញ បន្ទយ នាំចេញ

អក្ខរាវិរុទ្ធ:= បរិភោគ (គ) ល្មោភ (ភ) ថ្លុះ (ះ)

មន្ទីរ (រ) ពេទ្យ (ទ្យ) អាស្រ័យ (័) ។

សួរដេញ

– ត្រូវបរិភោគយ៉ាងដូចម្ដេចទើបបានសេចក្ដីសុខ ។

– មនុស្សស៊ីច្រើនមានគ្រោះថ្នាក់យ៉ាងណាខ្លះ ។

– នៅមន្ទីរពេទ្យគេច្រើនប្រទះ ឃើញមនុស្សមានគ្រោះថ្នាក់ដោយធ្វេសប្រហែសនឹងការបរិភោគដូចម្ដេចខ្លះ ។ល។

---

## មជ្ឈមដ្ឋានទី ២

### សេចក្ដីធ្វេសប្រហែសក្នុងការផឹក

មានអ្នកខ្លះឃើញតែទឹក ក៏ចេះតែផឹកក្អឹកៗ ទាំមិនប្រយ័ត្ន ជួនកាលមានហេតុនាំឲ្យមានគ្រោះថ្នាក់ក៏សឹងមាន ដូចជនខ្លះដែលចូលចិត្តផឹកទឹក

គ្រុបប្រថាប់ មានជួនកាលផឹកដោយទាំងគ្រាប់គ្រុបក៏មាន មានអ្នកខ្លះផឹកប្រញាប់ប្រញាល់ពេក ទៅជាឈ្លក់ស្រឡូកក៏មាន ហេតុនេះអ្នកធ្វើតោងតែប្រុងប្រយ័ត្ន អ្នកផឹកក៏តោរពិនិត្យមើលមុនទឹកផឹកនោះដែរ ។ មានអ្នកខ្លះខ្ជួនដាក់ធ្មេញ វេលាលេបថ្នាំគ្រាប់ជាមួយនឹងទឹក មិនបានប្រុងប្រៀបឲ្យហ្មត់ចត់ធ្មេញដែលដាក់ក៏របូតជ្រុះចុះបូល ទៅជាមួយនឹងគុលិកាជាប់ទៅក្នុងបំពង់កក៏មាន ។

ហេតុនេះត្រូវជៀសវាងសេចក្តីប្រមាទក្នុងការផឹកនឹងការស៊ី មានទំនង់ដូចជាយើងដើរចូលទៅក្នុងព្រៃក្បាដែលមានបន្លាប្រូងប្រាង យើងត្រូវតែដើរយ៉ាងសន្សឹមៗកុំស្រូកទម៉ិនឲ្យបន្លាមុតជើងយ៉ាងណា ការស៊ីនឹងការផឹក ក៏ត្រូវតែប្រុងប្រយ័ត្នដូច្នោះដែរ ។

លោក - ប - ឈុំ

ពន្យល់ពាក្យ:—

ស្រឡូក= ក. របូតអើលជ្រុលចូលទៅក្នុងបំពង់ក ។

ឈ្លក់ស្រឡូក.— ឈ្លក់អើលចូលក្នុងបំពង់ក ។

គុលិកា ឬ គុឡិកា= ន. ដុំមូលតូច ៗ ដុំថ្នាំម្យាប់ពេក ។

វេវចន, ពិនិត្យ.= វិនិច្ឆ័យ.ពិចារណា សង្កេតមើល..........

សទិសសព្ទ: ជាស— ន..សត្វជាសដូចបង្កួយ ។ ជៀស. ក. ជៀសវាងសត្រូវ ។

សណ្ឋានពាក្យ. ជ្រុះ = ជំរុះ = រុះ ។

អក្ខរាវិរុទ្ធ = ពិនិត្យ (ត្យ) ហ្មត់ (ហ្ម) ជ្រុះ (ះ) ប្រមាទ (ទ)

សួរចោទ— តាមវិធីបង្ការរោគ មុននឹងផឹកត្រូវធ្វើដូចម្ដេច? ។ ត្រូវផឹកយ៉ាងណាដើម្បីជៀសវាង គ្រោះថ្នាក់ក្នុងការផឹក ។

---

## មជ្ឈិមដ្ឋានទី ២

# អំពីរុយនឹងមូស

បណ្ដាសត្វតូចៗល្អិតជាសត្វមានកំឡាំងលើសមនុស្សយើងទៅទៀត តាមដោយសេចក្ដីរាវរកឬប្រទះតាមវិទ្យាសាស្ត្រនៅសព្វថ្ងៃនេះ ។ សត្វតូចៗអស់នេះហើយដែលបណ្ដាលឲ្យកើតទុក្ខវេទនាដល់ មនុស្ស ជាតិជាយ៉ាងច្រើន ។

ចំពួកសត្វរុយនិងសត្វមូស ដែលយើងប៉ះពាល់ឬទះដោយដៃ វាក៏ស្លាប់មួយរំពេច ប៉ុន្តែសត្វអស់នេះហើយជាហេតុធ្វើឲ្យមានចំនួនសត្វ ក្នុងសកលពិភពស្លាប់ទៅដល់ពាក់កណ្ដាលរាល់ៗឆ្នាំ ដោយវាមកទំឬខាំអវយវៈយើងក៏មាន ដោយវាទៅទំនៅលើចំណីអាហារឬទំលើផ្លែឈើទុំ ដែលយើងបរិភោគធ្វើឲ្យអាហាររបស់យើងមិនស្អាត ស្មោកគ្រោកកើតទោសដល់អ្នកបរិភោគក៏មាន ។

យើងដឹងច្បាស់ថា ជម្ងឺគ្រុនចាញ់ដោយមកអំពីសត្វមូសដែលមានជម្ងឺគ្រុនចាញ់ដែរ ។

សត្វពីរចំពូកនេះជាសត្វសាហាវបំផុតនៅលើផែនដី ។

លោក ប. ឈុំ

## ពន្យល់ពាក្យ

វិជ្ជាវិទ្យាសាស្ត្រ= គឺវិជ្ជាដែលគេរកឃើញដោយការលៃផ្សំមានការផ្សំធាតុជាដើម ។

សកលឬសាកលពីភព= ទូទៅក្នុងលោកទាំងមូល

វេវចនៈ— អាហារ- ភោជន- ម្ហូប ។

សទិសសព្ទ:ករ.កិ. —ការចាប់ត្រី ។ ន. ការចាន ។ គុ. រៀវ-ការរៀវ

អក្ខរាវិរុទ្ធ: វិទ្យាសាស្ត្រ (ស្ត្រ)—ទុក្ខ (ក្ខ) បរិភោគ (គ) ។

ស្វរពោធ— ពីព្រោះអ្វីបានជាថាសត្វតូច ៗ ល្អិតមានកំឡាំងលើសមនុស្ស ។

សត្វណាខ្លះដែលធ្វើឲ្យមនុស្សមានទុក្ខវេទនា ។

យេបណ្ដាលហេតុដូចម្ដេច ៗ មូសបង្កើតរោគអ្វីខ្លះ ។

## មជ្ឈមដ្ឋានទី ១

## រៀនមើល - ហាត់ភាសា

### អត្ថបទទី១.– បុត្រធីតានឹងមាតាបិតា

បែបបទដែលបុត្រធីតា ត្រូវគោរព ត្រូវទំនុកបំរុងមាតាបិតាវិញ មានប្រាំយ៉ាងៈ

១– បញ្ចឹមរក្សាមាតាបិតាដោយពេញលេញ ឲ្យដូចកាលមាតាបិតាបញ្ចឹមរក្សាខ្លួន ឬបើមានលើសជាងនោះទៅទៀត ក៏រឹតតែប្រសើរណាស់ ។

២ ធ្វើកិច្ចការជំនួសមាតាបិតា មិនគោះតើយ សោះអង្គើយបណ្តែតបណ្តោយឲ្យមាតាបិតានឿយហត់ដល់ចាស់ ទោះបីខ្លួនមានស្វាមីភរិយាបែកមុខការរបរចេញឃ្លាតពីមាតាបិតាហើយ ក៏ត្រូវតែជួយធ្វើកិច្ចការរបស់មាតាបិតាតាមកាលវេលាម្តង ៗ ដែលគួរនឹងខានពុំបាន ។

៣– តាំងវង្សត្រកូលល្អរបស់មាតាបិតាឲ្យគង់នៅ គឺមិនបំបាត់សណ្តាប់ធ្នាប់ល្អរបស់មាតាបិតាឲ្យវិនាស មិនប្រព្រឹត្តល្មើសរំលងផ្លូវល្អរបស់មាតាបិតា មិនធ្វើឲ្យអ្នកមានគុណកើតទុក្ខព្រួយចិត្តព្រោះខ្លួន ។

៤- គោរពប្រតិបត្តិឲ្យល្អមមាតាបិតាពេញចិត្ត ឲ្យទ្រព្យសម្បត្តិកេរ្តិ៍ស្រាប់ ប្រយ័ត្នរក្សាទ្រព្យសម្បត្តិកេរ្តិ៍អាករ ដែលមាតាបិតាចែកឲ្យ មិនបំផ្លាញឲ្យវិនាសអសារឥតការ ។

៥- លុះឥតអំពីមាតាបិតាទៅ បានលើកសពសំស្ការដោយគោរព បានធ្វើទក្ខិណានុប្បទាន ឧទ្ទិសផលបុណ្យជូនរឿយ ៗ ។

មាតាបិតានឹងបុត្រធីតា ដែលបានបំពេញកិច្ចរបស់ខ្លួនតាមបែបបទដូចមាននិទានមកនេះ ទើបពេញជាបុគ្គលកតញ្ញូកតវេទីត្រឹមត្រូវ ។

(មើលមេរៀនខទី៦អំពី "មាតាបិតានឹងបុត្រធីតា" ផង)

## អាននឹងពន្យល់ពាក្យ

គោរព= ន.ឬក. សេចក្តីលំអុត ឱនលំទោន-កោតក្រែង ។

ឱវាទ= ដំបូន្មាន ៗ ស្តាប់ឱវាទ ។

អាករ= កំណប់ទ្រព្យ

អសារ= (ម.ប.អៈសារ) ដែលឥតខ្លឹមឥតប្រយោជន៍ ។

សំស្ការ= (ម.ប.ស័ង្ស្ការ) សំពម (លើកសពសំស្ការគឺលើកខ្មោច រើសប្រមូលឆ្អឹងយកមកធ្វើបុណ្យ)

ទក្ខិណានុប្បទាន= (ម.ប.ទ័កខិណានុបបៈទាន) ន. អំណោយ

ដែលគេឧទ្ទិសផលនៃទក្ខិណាទាន ទៅបុគ្គលដែលចាកឋានទៅកាន់បរលោកហើយ ។

បុព្វការី=(អ.ថ.បុព្វៈការី) ន. អ្នកដែលធ្វើឧបការៈមុនមាតាបិតាជាបុព្វការីរបស់កូន ។ គ្រូជាបុព្វការីរបស់សិស្ស ។

កតវេទី= ន.ឬគុ. អ្នកដែលគិតតែនឹងតបស្នងសងគុណដល់អ្នកមានគុណ ។

សួរចោទ. បែបបទដែលបុត្រធីតា ត្រូវខំនុកបំរុងមាតាបិតាមានប៉ុន្មានយ៉ាង? បទទី១ត្រូវធ្វើដូចម្តេចខ្លះ? មនុស្សក្នុងលោកដែលប្រព្រឹត្តតាមបទទី១មានចំនួនច្រើនឬតិច ។ល។

## តែងសេចក្តី

ចូរអធិប្បាយអំពីកិច្ចដែលអ្នកត្រូវបំពេញ ដល់មាតាបិតាអ្នកនឹងបានពេញជាបុព្វការី កតញ្ញូ កតវេទីត្រឹមត្រូវ ។

## សេចក្តីសប្បុរស

ខ្មែរជាអ្នកកាន់ព្រះពុទ្ធសាសនា តែងប្រដៅកូនចៅឲ្យកាន់សប្បុរសនឹងលោកសង្ឃ នឹងស្មូមយាចក ហើយអាណិតមេត្តាដល់អ្នកកំសត់ទុគ៌ត

តោកយ៉ាកលំបាកផង ។ ហេតុដូច្នេះបានជាគេឃើញខ្មែរធ្វើបុណ្យឲ្យទានជារឿយៗនៅក្នុងវត្តអារាម ហើយគេជួយមនុស្សក្រីក្រ តោកយ៉ាកលំបាកឲ្យអាហារចិញ្ចឹមជីវិត ហើយនិងសម្លៀកបំពាក់ល្មមសមគួរផង ។

ខ្មែរតិះតិះដៀលមានចិត្តអសប្បុរស អកតញ្ញូ និងអ្នកដ៏មានគុណមានមាតាបិតា គ្រូអាចារ្យហើយនិងអ្នកដែលជួយទំនុកបំរុងចុងផ្ដើមឲ្យបានប្រយោជន៍ផ្សេងៗជាដើម ។ គេមិនរាប់អានមនុស្សដូច្នេះសោះឡើយ គេស្អប់ហើយគេមិនយកជាមិត្រសំឡាញ់ទេ ។

ទោះជាមានសេចក្ដីទូន្មានល្អ ប្រកបដោយធម៌ដូច្នេះ ក៏គង់នៅមានមនុស្សខ្លះមានចិត្តកំណាញ់ណាស់ ។ មនុស្សខ្លះមិនដែលធ្វើបុណ្យឲ្យទានសោះ ហើយកំណាញ់និងខ្លួនឯងផង ។

ហាត់ភាសា — ខ្មែរជាអ្នកកាន់សាសនាអ្វី ? ខ្មែរតែងប្រដៅកូនចៅឲ្យប្រព្រឹត្តដូចម្ដេច ? ខ្មែរតិះតិះដៀលមនុស្សបែបណា ? គេស្រឡាញ់រាប់អានមនុស្សយ៉ាងនោះឬទេ ? ។

---

អានិកផ្លាន

## បង្រៀនពាក្យនឹងភាសា

អាទិត្យទី ១ — អំពីរុក្ខជាតិដែលមានសរសៃត្បាញបាន

នាម — កប្បាស គរ ធ្មៃ ម្នាស់ ចេក ត្រគៀតប៉ោង កៅស៊ូ ឫស្សី សំឡី ជ័រ សរសៃអន្ទង សរសៃហាក់ កី ផ្ដោះបោះកប្បាស សម្លៀកបំពាក់សំពត់អំបោះ ។

គុណនាម — ទន់ រឹង ស្វិត យឺត ជាប់ ផុយ មាំ ធ្មារ ថោស រលីង រលើប គគ្រាត ។

កិរិយាសព្ទ — កាត់ខោ-អាវ ដេរសម្លៀកបំពាក់ ដោះកប្បាស ត្រាំក្រចៅ.- ធ្មៃ រវៃអម្បោះ ផ្ដួចសំឡី ខារអំបោះ អន្ទង់ត្បាញ សកសំបក

ហាត់ភាសា — សម្លៀកបំពាក់ដែលយើងស្លៀកពាក់សព្វថ្ងៃបាន មកពីអ្វីខ្លះ? (បានមកពីរុក្ខជាតិនិងសត្វ) អ្នកស្គាល់រុក្ខជាតិអ្វីខ្លះដែលមាន សរសៃត្បាញបាន? នៅភូមិអ្នកមានគេដាំកប្បាសឬទេ? គេដាំកប្បាស ច្រើននៅឯណា? កាលណាផ្លែកប្បាសបែករីកគេធ្វើដូចម្ដេច? គេយក កប្បាសទៅធ្វើដូចម្ដេចទើបបានជាសំឡី? ខ្មែរយកសំឡីកប្បាសទៅធ្វើអ្វី? (យកទៅធ្វើអម្បោះក្លួយ ត្បាញសំពត់សម្រាប់កាត់ខោ-អាវ ធ្វើជាក្រមា ផ្លូតទឹកធ្វើស្បៃមុង ។ល។

ការហាត់សរសេរ — ចូរឆ្លើយឲ្យប្រកបនឹងពាក្យសួរខាងក្រោមនេះ៖

សម្លៀកបំពាក់ប្រើប្រាស់សព្វថ្ងៃបានមកពីអ្វីខ្លះ? រុក្ខជាតិណាខ្លះ ដែលមានសរសៃត្បាញបាន? ។

## បង្រៀនមើល

( សៀវភៅវិត្ថុស្វាធ្យាយន៍អាទិកដ្ឋានទំព័រ ១៥០ )

### សិប្បីយការកើតពីសត្វ

ហាត់ភាសា = សំពត់សូត្រយ៉ាងល្អគេធ្វើនឹងអ្វី ? ដើម្បីស្រាវយកសរសៃសូត្រអ្នកស្រុកអាយធ្វើដូចម្ដេចខ្លះ ? ព្រោះអ្វីបានជាគេយកសំបុកសូត្រទៅស្រុសក្នុងទឹកពុះ ហើយកូរនឹងចង្កឹះ ? គេស្រាវសូត្រនឹងអ្វី ? ស្រាវរួចហើយគេធ្វើដូចម្ដេចទៀត ? ។ល។

## សរសេរតាមសូត្រ

### ដើមកប្បាស

ដើមកប្បាសជារុក្ខជាតិតូច កំពស់មួយម៉ែត្រ ឬមួយម៉ែត្រកន្លះ គ្រាប់វាសម្បុរសឬលឿងមានសំឡីរុំព័ទ្ធជុំវិញ ផ្លែវែបជាឡូតមានគ្រាប់នឹងពេមទន់ល្មើយនៅក្នុង គឺពេមនោះហើយដែលហៅថាសំឡី ។ កប្បាសដុះលើដីធួរ ហើយមានជីជាតិច្រើនផង ។

គេដាំកប្បាសនៅខែបុស្ស-មាឃ ហើយគេបេះយកផ្លែនៅខែជេស្ឋ អាសាធ ។ នៅស្រុកខ្មែរគេដាំកប្បាសនៅមាត់ទន្លេមេគង្គ ក្នុងខែត្រកំពង់ចាមនឹងខែត្រកណ្ដាល ។

កប្បាសសម្រាប់ត្បាញធ្វើជាសំពត់ហៅថាសំពត់អម្បោះ គេយកគ្រាប់វាទៅស្លប្រេងសម្រាប់អុជលាងម៉ាស៊ីន ហើយទឹងធ្វើសាប៊ូ កាកសម្រាប់ធ្វើជី ។

សរសេរពាក្យពីបាក — កប្បាស រុក្ខជាតិ សម្បុរស រុំ ព័ទ្ធ ផ្ទុះ បុស្ស មាឃ ជេស្ឋ អាសាធ កំពង់ កណ្ដាល ទន្លេ ប្រេង អុជ លាង ។

## តែងសេចក្ដី

ចូរឆ្លើយតាមពាក្យចោទសួរខាងក្រោមនេះ ៖

ពោតជាដំណាំគេដាំយកអ្វី ? ដើមវាមានកំពស់ប៉ុន្មានម៉ែត្រ ? ស្លឹកវាយ៉ាងដូចម្ដេច ? ផ្លែវាមានប៉ុន្មានយ៉ាង ? នៅដើមនិមួយ ៗ មានផ្លែប៉ុន្មាន ? គ្រាប់ពោតមូលមានពណ៌ដូចម្ដេច ? ពោតមានប្រយោជន៍ដូចម្ដេចខ្លះ ? ។

## អក្សរផ្ចង់

ព ឮ ឰ ឈ ញ ឱ

ពពែញី ស្រុកពញាឮ ឮគេហៅ

ឰដ៏កាលណោះ ចៅពញារក្សាភិបាល

## រៀនពាក្យ - ហាត់ភាសា

### អាទិត្យទី ៦ - អំពីរោងកិនស្រូវ

នាម - ស្រូវ ស្រូវខ្សាយ ស្រូវដំណើប អង្ករ អង្កាម ម្សៅ កន្ទក់ ត្បាល់ជាន់ (ត្បាល់កឿង) ត្បាល់កិន ត្បាល់បុក អង្រែ កញ្ច្រែង កញ្ជើ ល្អី ផាវ ការុង រោងម៉ាស៊ីន ( រោងចក្រ ) ។

គុណនាម - ធ្ងន់ ស្រាល រហ័ស យឺត ខ្ជប ល្អិត ម៉ដ្ឋ ជ្រាយ ខ្មៅ ស ។

កិរិយាសព្ទ - កិន ជាន់ បុក បក់ផ្លុំអង្កាម រែងកន្ទក់ ហាលស្រូវ រោយស្រូវ ។

ហាត់ភាសា .- គេធ្វើដូចម្ដេចដើម្បីយកអង្កាមចេញ ? ត្បាល់កិនខាងលើ - ខាងក្រោមយ៉ាងដូចម្ដេច ? គេធ្វើទីងអ្វី ? ដើម្បីកិនស្រូវ គេដាក់ដៃត្បាល់នៅឯណា ? គេប្រកស្រូវនៅឯណា ? ត្បាល់ខាង

ក្រោមត្បាល់ទៅនឹងអ្វី ? ស្រូវកិនរួចហើយគេធ្វើដូចម្ដេចទៀត ? ត្បាល់ជាន់បែបយ៉ាងដូចម្ដេច ? អ្នកដែលជាន់អង្ករដែរឬទេ ? គេជាន់ប្រហែលប៉ុន្មានអង្រែទើបអង្ករស ? ។ល។

ការហាត់សរសេរ .— ចូរតែងជាឃ្លានឹងពាក្យខាងក្រោមនេះ ៖

ស្រូវ - អង្ករ - អង្កាម - កន្ទក់ - ម្សៅ ។

ឧទាហរណ៍ ពីម្សិលមិញខ្ញុំជួយកិនស្រូវបងស្រីខ្ញុំអស់ចំនួនប្រាំថាំង ។ គេយកអង្ករសំរូបទៅជាន់ឬបុកឲ្យសធ្វើជាអង្ករសំរិត ។

## បង្រៀនមើល

## រោងកិនស្រូវ

( សៀវភៅវត្ថុស្គាល់ឡាយន៍អេទិកផ្លានទំព័រ ៣២ តាំងពីមុននឹងយកស្រូវមកប្រើការ ....រហូតដល់ ..... ឯនៅស្រុកហាណូយនឹងហៃហ្វុងហើយនឹងភ្នំពេញ គេឃើញមានរោងកិនស្រូវដែរ ។

ពន្យល់ពាក្យ.— កិន = កិ. សង្កត់ឲ្យបែក: កិនស្រូវ កិនគ្រួស ។ ជាន់ = ដាក់ជើងសង្កត់ស៊ប់ពីលើ ។ ជាន់អង្ករឬបុកអង្ករនឹងត្បាល់ជាន់ឬនឹងត្បាល់បុក ។

កញ្ច្រែង = ១. ប្រដាប់ប្រើ ត្បាញនឹងបន្ទោះ ដូច ល្អី កញ្ជើ តែត្បាញរង្វើល ២. កញ្ច្រែងកាន់ជ្រៅប្រហោងធំសំរាប់ដាក់ត្រី, កញ្ច្រែងពងកក់ប្រហោងតូចៗសម្រាប់រែងអង្ករ ។

ត្បាល់ = ១. ប្រដាប់សម្រាប់ប្រើខាង,បុក កិន,ជាន់,បក់ស្រូវជាដើម ៗ ល ៗ ត្បាល់មានច្រើនយ៉ាង : ត្បាល់កិនមានមេត្រុបតៅ ឆ្វេញ ដែលសម្រាប់កិនស្រូវជាដើម ៗ ល ៗ

ត្បាល់ជាន់ឬត្បាល់ក្តឿង ត្បាល់ដែលមានអង្រែជាប់នឹងដងសម្រាប់ជាន់បុកស្រូវជាដើម ៗ

## សរសេរតាមសូត្រ

### ហាលស្រូវ

កាលពីថ្ងៃអាទិត្យមុន មេឃស្រឡះព្រះអាទិត្យបញ្ចេញចំហាយខ្លាំងណាស់ ម្តាយខ្ញុំបាទប្រើបងខ្ញុំនិងខ្ញុំឲ្យហាលស្រូវព្រោះជិតអស់អង្ករបរិភោគហើយ នោះបងខ្ញុំហើយនិងខ្ញុំបាទក៏យកកន្ទេលស្លឹកត្នោតមួយធំទៅក្រាលលើដីមួយកន្លែងរាបស្មើក្នុងទីធ្លា រួចយកកញ្ជើមួយកើបស្រូវពីជង្រុកប្រហែលជាបីចាំង ទៅចាក់ដាក់លើកន្ទេលនោះ ហើយរាបស្រូវ

ឲ្យមានកំពស់ស្មើគ្នា ទាំងអស់ពេញកន្ទេល ខំបាចទៅចាំមើលកុំឲ្យមាន់ទា មកស៊ីមកហូស្រូវ ហើយទំរីស្រូវម្តងៗផង ដើម្បីឲ្យស្ពុះសព្វទាំងអស់

អក្ខរាវិរុទ្ធ.- អាទិត្យ មេឃ បរិភោគ បញ្ចេញ ពបស្មើ កញ្ជើ - ជម្រក - វាប - សព្វ ។

## តែងសេចក្តី

ចូរអ្នកអធិប្បាយអំពីការធ្វើអង្ករ តាំងពីហាលស្រូវកិនស្រូវដកពបដល់បាន ជាអង្ករស ( អង្ករសំរិត ) តើខ្មែរយើងធ្វើយ៉ាងម្តេចខ្លះ ? ការនេះជាការ នឿយហត់ច្រើនឬទេ ? អ្នកយល់ឃើញដូចម្តេច ? ។

### ទំនងតែង

សេចក្តីផ្តើម.- (វេលាណាគេហាលស្រូវ វេលានោះគេធ្វើដូចម្តេចខ្លះ) ។

- សេចក្តីរៀបរាប់.- គេកិនស្រូវនឹងអ្វី ? គេធ្វើយ៉ាងដូចម្តេច? គេជាន់អង្ករនឹងអ្វី ? គេអុំរែងឬបក់នឹងអ្វី ? ព្រោះអ្វីបានជាគេអុំរែង?

យោបល់របស់អ្នក.- អ្នកយល់ឃើញដូចម្តេច ? ការនេះនឿយហត់ច្រើនឬទេ ? គេធ្វើដូចម្តេចវិញដើម្បីឲ្យងាយជាងនេះ ?

## អក្សរផ្ចង់

ង ជ ឌ ផ ឯ ងងុយដេក ងេងងោង ផ្ងួជក់ដើរផុង ដកដង្ហើមផេតផិត

## រៀនពាក្យនិងភាសា

អានិត្យទី៣·— **អំពីថ្នាំ**

នាម.- គ្រាប់ថ្នាំ ផ្លែថ្នាំ ស្លឹកថ្នាំ កូនថ្នាំ ថ្នាល រមូរ ស្លឹកថ្នាំ សរសៃថ្នាំ ជ្រុញ កាំបិត ថែប ខ្សៀ បារី ។

គុណនាម·— ខ្លាំង ខ្សោយ មូល ស្ដើង ក្រាស់ ឆ្ងារ ថ្លោស ស្ងួត សើម ។

កិរិយាសព្ទ.— ព្រោះគ្រាប់ថ្នាំ ដាំកូនថ្នាំ បេះស្លឹកថ្នាំ បន្ទុំថ្នាំ ហាន់ថ្នាំ ហាលថ្នាំ យកសន្សើមថ្នាំ មូរបារី បុកថ្នាំ ញាត់ខ្សៀ ជក់បារី ។

ហាត់និយាយ.— ថ្នាំជាដំណាំគេដាំយកអ្វី? ដើម្បីដាំថ្នាំគេធ្វើដូចម្ដេច? ពេលណាដែលគេដកកូនថ្នាំយកទៅដាំក្នុងចំការ? គេដាំថ្នាំចម្ងាយពីគ្នាប្រហែលប៉ុន្មានសង់ទីម៉ែត្រ? ដាំរួចហើយគេធ្វើដូចម្ដេចទៀត?

កាលណាដែលគេបេះស្លឹកថ្នាំ? គេបេះស្លឹកថ្នាំយកទៅធ្វើដូចម្ដេចខ្លះ? ដើម្បីមូរជាបារីបាន? គេហាន់ថ្នាំទំងស្វី? ហាន់ថ្នាំរួចហើយគេធ្វើដូចម្ដេចទៀត?

## បង្រៀនមើល

សៀវភៅដែលទំព័រ១៣៩ តាំងពី គេបេះស្លឹកថ្នាំហើយគេយកមករុំជាមួរបន្ទុំទុកក្នុងម្លប់....រហូតដល់...គេដាំថ្នាំមិនបានចំនួនគ្រប់គ្រាន់អាស្រ័យទេ ។

ពន្យល់ពាក្យ.- ថែប=ន. ផែនធ្វើពីឬស្សី,បបុសឬស្លឹកត្នោត, ស្លឹកចាកជាដើមសម្រាប់ហាលថ្នាំ ។

ថែប= កិ. ប៉ះដែកល្អនឹងដែកអន់ដើម្បីឲ្យមុត ។

ថែប= ន. ដែកគាស្សប្អូដែកគាសៀក; ដែកថែប ។

## សរសេរតាមសូត្រ

### ការធ្វើថ្នាំ

គេដាំថ្នាំគ្រប់តែកន្លែងនៅក្នុងប្រទេសឥណ្ឌូចិន ។

ថ្នាំជារុក្ខជាតិមានកំពស់ដល់មួយម៉ែត្រកន្លះ ស្លឹកធំផ្កាពណ៌ក្រហមព្រឿងៗប្រស្វាយ ផ្លែគោបមានគ្រាប់តូចៗ នៅខាងក្នុង ។

គេបេះស្លឹកថ្នាំហើយយកមកបន្ទុំក្នុងម្លប់ រួចហូតយកទ្រនុងចេញ ទើបហាន់ជាសរសៃឆ្មារៗ ឯហាន់នោះគេហាន់នឹងជ្រុញសម្រាប់ហាន់ថ្នាំៗ គេដាក់រមូរស្លឹកថ្នាំក្នុងប្រហោងជ្រុញ ហើយគេរុញបន្តិចៗទៅមុខ ។

សរសៃថ្នាំដែលគេហាន់យ៉ាងដូច្នេះហើយ ត្រូវយកទៅផ្ទុះហាលលើថែវ ថែវនោះគេធ្វើពីឫស្សីឬទឹងបុស គេហាលថ្ងៃ ហាលសន្សើមបានពីរបីថ្ងៃ ថ្នាំនោះស្ងួតហើយមានពណ៌ក្រហមព្រឿងៗ ។

ថ្នាំសម្រាប់ជក់ឬបុក គេជក់ថ្នាំនឹងខ្សៀឬមូរបារីតូចៗ ។

## តែងសេចក្តី

ចូរអធិប្បាយអំពីការធ្វើថ្នាំ ដែលអ្នកបានឃើញឬបានឮគេនិយាយ តើការនោះគេធ្វើដូចម្តេចខ្លះ? តាំងពីដាំថ្នាំឡើង រហូតដល់បេះស្លឹកហាន់បានជាសរសៃ រួចហាលបត់បានជាផ្ទៅឬបាញ់ថ្នាំស្រប អ្នកយល់ឃើញថាគួរដាំថ្នាំឲ្យបានច្រើនឬទេ នៅស្រុកយើង? ។

## ទំនងតែង

–សេចក្តីផ្តើម.– ( នៅភូមិអ្នកមានគេដាំថ្នាំឬទេ? វេលាដែលគេព្រោះគ្រាប់ថ្នាំ គេធ្វើដូចម្តេច? ) ។

–សេចក្តីកប់រៀប.– គេដកកូនថ្នាំទៅដាំក្នុងចំការគេធ្វើដូចម្តេចខ្លះ? ការថែកូនថ្នាំ គេធ្វើដូចម្តេចខ្លះ? គេបេះស្លឹកថ្នាំយ៉ាងណា ហើយគេធ្វើដូចម្តេចខ្លះ? ការហាន់ថ្នាំនិងហាលថ្នាំ គេធ្វើដូចម្តេច? គេយកសរសៃថ្នាំមកធ្វើដូចម្តេច? ។

–សេចក្តីបញ្ចប់.– អ្នកយល់ឃើញដូចម្តេចអំពីការធ្វើថ្នាំ? ។

## អក្សរផ្ចង់

ង ជ ដ ធ ឯ កុំផឹកដោក កុំដេកទាល់ថ្ងៃ កុំជក់បារីក្នុងមុង

អាទិត្យទី ៤.– សុំឲ្យសាបស្រៀនពីដើមឡើងវិញ

---

បរិច្ឆណាដ្ឋាន

## បង្រៀនពាក្យនិងភាសា

## អាទិត្យទី ១– ការធ្វើស្ករ·

ពាក្យ– ទឹកអំពៅ,ទឹកត្នោត,អំពៅ,ត្នោត,ឃ្នាប, ដំបៀត, កាំបិត, បំពង់,បង្អោង, គុក, ខ្ទះ; ពុម្ព, ក្អម, ពាង, ស្រាក់ស្ករ ។

គុណនាម– ផ្អែម, ជូរ, ខាប់, រាវ, ស, ខ្មៅ, លឿង, ក្រហម, ព្រឿង, មូលសំប៉ែត, ស្រួយ,ផ្អាប, ឈ្ងុយ, ក្រអូប; ល្អិត, រអិល,

កិរិយា–សក, គាប, សំរក, ត្រង, រំងាស់, រិត, បំពង, ចាក់ស្ករ, ស្រាក់ស្ករ, បង្ខះ, រលាយ, កក, ។

ភាសា– បង្ហាញស្ករគ្រប់យ៉ាង រួចហើយទើបចោទ្យសួរ ។ រុក្ខជាតិអ្វីខ្លះដែលមានទឹក ឯម ផ្អែម?

រុក្ខជាតិអ្វីនៅស្រុកខ្មែរ ដែលឲ្យទឹកផ្អែមច្រើន? ស្ករមានសណ្ឋាន ដូចម្តេចខ្លះ?

## អាទិត្យទី ២– ការធ្វើប្រេង

ប្រេងដូង, ប្រេងល្ហុង, ប្រេងសណ្តែក, ប្រេងល្ង, ប្រេងសំពោង, ខ្លាញ់គោ, ខ្លាញ់ជ្រូក ។ ដូង, ល្ហុងខ្វែរល្ង, សណ្តែកដី, សំពោង ។ ដ័រទឹក, ត្រាប, ឈើតាល ។ ដ័រពារ. ម្រក្សណ៍ ។

គុណនាម–ល្អិត ខាប់ រាវ ស្អិត ថ្លា ព្រឿង ខ្មៅ រលោង រលើប ស្រិល ។

កិរិយា– ស្ងោរប្រេង ចំហុយ ចំហៀរ កិនសង្កត់ ដួស កោស បុក ដង់ដរ ទុក ពរ លាប តុប លំអិល គ្រឿង បគ្រ លាបថ្នាំ ធា បៀនអាហារៗ

អាទិត្យទី ៣– អំពីជ្រលក់-ប្រហុក-ស្បែក

នាម– ពណ៌ មក្លឿ ស្បែង ស្លាប់ ព្រហូត ផ្អូ ត្រុំ រមៀត ទុរៗ ប្រហុក ផ្អក ផ្អៀត កាពិ ត្រីបង្កា ត្រីប្រា ស៊ៃ ផ្ដា ព្រួល បវបល កំពិស ប្រោន ៗ ស្បែកគោ ស្បែកក្របី ស្បែកក្រពើ ស្បែកថ្លាន់ ស្បែកពស់ ប្រមោយដំរី ស្បែកខ្លា ស្បែកឈ្លូស ប្រើស ក្ដាន់ ៗ ស្បែកសម្លាប់ ហិបស្បែក ស្បែកជើង គ្រឿងរំបសេះ ស្រោម ស្គរ កំភល ពស្រ្ដា ៗ

គុណនាម–ព័ណ៌ខៀវ ខ្មៅ លឿង បៃតង ក្រហម ផ្អូ ស្វាយ ៗ ប្រហុកខ្លោះ ខុល ល្អ ឈ្ងុយ ៗ ប្អូកផូរ ប្រៃ សាប គាពិស្អុយ ម៉ដ្ឋ អាក្រក់ ៗ ស្បែកផាប់ ស្វិត ក្រាស ៗ ស្តើង គគ្រាត គគ្រើម ពទឹក ពញាក់ ៗ

កិរិយា–ជ្រលក់ ត្រាំ សម្ងាប់ កួរ បុក រំអាស់ ប្រឡាក់ ហាល វះ ស្រកាវ ពន្លះ ដេរ កាត់ បៀរ វាស់ ពាស ទឹម ៗ

អាទិត្យទី ៤–

សុំបង្រៀនពាក្យភាសាពីអាទិត្យមុន ១ ឡើងវិញ ៗ

# រៀនមើល

## អាទិត្យទី ១- ការធ្វើស្ករ

(វត្តស្វាផ្សាយទំព័រ ១៣៦ ។)

ពន្យល់ពាក្យ- ប្រទេសឥណ្ឌូចិន= តំបន់មួយស្រុកខ្មែរ យួនអណ្ណាម យួនតុងកឹង យួនកូសាំងស៊ីន និងលាវ ។

ឃ្នាប -ប្រដាប់សម្រាប់គាប ។ ពុម្ព-គឺធ្វើដោយស្លឹកត្នោតសម្រាប់ចាក់ស្ករឲ្យបានជាស្ករផែន ។

អានពាក្យ-ព្រោះ-ឲ្យអានថាប្រស់-អម្បោះ ព្រោះ គ្រោះ ។

ពាក្យសួរ-ក្នុងប្រទេសឥណ្ឌូចិនគេធ្វើស្ករនឹងទឹកអ្វី? គេធ្វើដូចម្ដេច ទើបបានទឹកពីអំពៅ? ពីត្នោត? គេយកទឹកត្នោតឬទឹកអំពៅទៅធ្វើម្ដេចទៀតទើបបានជាស្ករ?

## ២-អំបិល.

(សៀវភៅដដែលទំព័រ ១១៤)

កែតម្រូវពាក្យ=ស្រមុទ្រជាសមុទ្រ ច្បូងជាត្បូង ។ សុំឲ្យតែងសេចក្ដីពោធសួរផងចុះ ។

អាទិត្យទី២– ត្រឡប់មករកចិញ្ចឹមជីវិតនៅស្រុកស្រែ.

(វិជ្ជាខេមរៈ–បង–ទំព័រ ៨១)

ការជ្រលក់សំពត់ (វត្ថុស្នា–បង–ទំព័រ ១៥២ ដល់ហៅមរ)

ពាក្យប្រើញឹកញយ– អម្បោះ ពណ៌ រមៀត ព្រហូត ខ្ទរ

ផ្គួពកែខសូត្រសប្បុយការ ។

## ការជ្រលក់សំពត់ (ត) ដល់ចប់

គោលតម្រូវពាក្យ–ក្រីជាគ្រី សរជាស អាចជាអាចម៍ ។

អាទិត្យទី ៣– ១ ស្លូបត្រី (វិជ្ជាខេមរៈ–បង–ទំព័រ ៩៣ )

២– ធ្វើប្រេងហើយនឹងសាប៊ូ (វត្ថុស្នា–បង–ទំព័រ ១៣៧)

៣– ការនេសាទត្រីនៅទន្លេសាប (វិជ្ជាខេមរៈ–បង–ទំព័រ ៩៥)

អាទិត្យទី ៤–

១– ការនេសាទត្រីនៅទន្លេសាប (ត) វិជ្ជាខេមរៈ–បង–ទំព័រ ៩៧)

២– ការសម្លាប់ស្បែក (វត្ថុស្នា–បង–ទំព័រ ១៦៤). ។

---

កុមារដ្ឋាន

**រៀនមើលបាត់ភាសា**

អាទិត្យទី ១ អំពីពេល

ពាក្យ– ព្រឹក, ល្ងាច, ព្រលប់, អធ្រាត្រ; ថ្ងៃ, យប់, ថ្ងៃត្រង់, ព្រហាម, ព្រលឹម, ល្ងាចត្រជាក់, ព្រលប់ងងឹត, យប់ងងឹត, ថ្ងៃភ្លឺ: ភ្ញាក់ពីព្រឹក, ទៅពីព្រហាម, មកតាំងព្រលឹម ។

ភាសា– ព្រលឹមឡើងអ្នកធ្វើអ្វីខ្លះ? វេលាយប់អ្នកធ្វើអ្វីខ្លះ? ឪពុកម្ដាយអ្នកធ្វើអ្វីខ្លះក្នុងវេលាថ្ងៃ ?

អាទិត្យទី២.– ពេល (ត)

ពាក្យ– ថ្ងៃនេះ, ថ្ងៃមុន, ម្សិល, ម្សិលម៉្ងៃ ម្សិលម៉្ងៃមួយ-នាយ ស្អែក ខានស្អែក ខានស្អែកមួយ ។ ថ្ងៃក្ដៅ យប់ ត្រជាក់ ព្រលប់ល្ហើយ អធ្រាត្រត្រជាក់ អធ្រាត្រស្ងាត់ ។ ទៅស្អែក មកថ្ងៃនេះ ។

អាទិត្យទី៣.– ពេល (ត)

ពាក្យ– អាទិត្យ ចន្ទ អង្គារ ពុធ ព្រហស្បតិ៍ សុក្រ សៅរ៍ ខែ ខ្នើត រនោច ពេញបូណ៌មី ខែដាច់ ខែមានថ្ងៃ ៣០ ខែមានថ្ងៃ ២៩ មួយអាទិត្យ ។

អាទិត្យទី៤.– ពេល (ត)

ពាក្យ– ខែ មិគសិរ បុស្ស មាឃ ផល្គុណ ចេត្រ ពិសាខ ជេស្ឋ អាសាឍ ស្រាពណ៍ ភទ្របទ អស្សុជ កត្ដិក ។ ស្រែហូត វាល

សឿង ស្រូវទុំ ដីរឹង ដីស្ងួត ស្ទូកស្រស់ ដីសើម ៗ កប់ថ្ងៃ សាបស្រូវ ព្រោះស្រូវ ភ្ជួរស្រែ ច្រូតស្រូវ ដកសំណាប ទឹករង ៗ

ភាសា– សុំឲ្យគ្រូប្រាប់សិស្ស មិគសិរ ២៩ ថ្ងៃ ៗ បុស្ស ៣០ ថ្ងៃ ៗ មាឃ ២៩ ថ្ងៃ ផល្គុណ ៣០ ថ្ងៃ ចេត្រ ២៩ ថ្ងៃ ពិសាខ ៣០ ថ្ងៃ ជេស្ឋ ២៩ ថ្ងៃ ៗ អាសាឍ ៣០ ថ្ងៃ ៗ ស្រាពណ៍ ២៩ ថ្ងៃ ៗ ភទ្របទ ៣០ ថ្ងៃ ៗ អស្សុជ ២៩ ថ្ងៃ ៗ កត្ដិក ៣០ ថ្ងៃ បូករាប់ខែទាំង ១២ អ្នកស្រែតាំងធ្វើអ្វីពីខែជេស្ឋទៅ ? នៅខែមិគសិរអ្នកបានឃើញពណ៌វាល ដូចម្ដេច ?

អាទិត្យទី ១ ធីផទី២.– ពេលវេលា

| បង្រៀនមើល |
|---|

(សៀវភៅបឋមវិជ្ជាខេមរភាសាកុមារដ្ឋានទំព័រ ១២៣

អាទិត្យទី ៣ ធីផទី ៤ – យប់ អាទិត្យ ខែ ឆ្នាំ

(សៀវភៅដដែល ទំព័រ ១២៤)

# តែងសេចក្ដី

## សម្រាប់

## ប្រថមភូមិបំពេញវិជ្ជា

កម្មវិធីសំរាប់ខែ - ពិពណ៌នាអំពីបាតុភូត

សេចក្ដីលំនាំ - នៅក្នុងការធ្វើពិពណ៌នាអំពីបាតុភូត (ភ្លៀង ខ្យល់ពេលថ្ងៃរះឬ នៅអស្ដង្គតកាល) គេត្រូវចាប់រៀបអំពីបុព្វហេតុ ដែលកើតមុនកំណើតបាតុភូតជាដំបូង រួចទើបអធិប្បាយអំពីដំណាក់ផ្សេងៗ នៃបាតុភូតរហូតដល់ពេលដែលបាតុភូតរលត់បាត់ទៅវិញ ដោយរើសយក តែហេតុណាដែលប្លែកគួរឲ្យសង្កេតមកបរិយាយ ។

គេបញ្ចប់ការតែងដោយបញ្ជាក់អំពីការចម្រើន ឬការអន្តរាយដែលកើត ឬបណ្ដាលឡើងពីបាតុភូតនោះ ឬដោយបញ្ចេញការចាប់អារម្មណ៍ ឬយោបល់ផ្ទាល់ខ្លួនចំពោះបាតុភូតនោះ ។

សេចក្ដីតែងទី ១.- កាលពីថ្ងៃមុនមានខ្យល់ព្យុះបក់បោកជាខ្លាំងមកលើភូមិអ្នក ចូរអ្នកធ្វើពិពណ៌នាអំពីខ្យល់ព្យុះនោះ ។

ការរៀបចំ-

១- អ្នកបានពើបប្រទះនឹងខ្យល់ព្យុះនៅទីណា ? ពេលណា ? អ្នកបានដឹងជាមុនឬទេ ? ធាតុអាកាសដូចម្ដេច ? (ក្ដៅជាខ្លាំងស្ងើរតែរកខ្យល់

ផកផង្ហើមពុំបាន) មេឃមានសណ្ឋានដូចម្ដេច ( ងងឹត - ស្រទំ ) - ពពក ? ( ខ្មៅខ្ពឹលប្រពូនលើគ្នា ) - ក្ដៅធាតិ ? ( ឥតកំរើកស្លឹក ) ៗ

២ – ស្រាប់តែមានខ្យល់ផ្ទាក់មក ៗ ខ្យល់នេះបណ្ដាលឲ្យមានហេតុដូចម្ដេចខ្លះ ? (ធូលីហុយឡើងលាយជាមួយនឹងស្លឹករុក្ខជាតិ – ធាតុអាកាសត្រឡប់ជារហើយស្រួលក្លាម) គេឮសូរស័ព្ទអ្វីខ្លះ? (សូរផ្គរលាន់រើយៗឯលើមេឃ) តើអ្នកដំណើរនិងកសិករធ្វើដូចម្ដេច ? (ខំស្រូតដំណើរខ្លះរត់រកទីជំរក អ្នកផ្ទះធ្វើអ្វី ? បិទទ្វារបង្អួច - សាត់រាណ់ទុក ស្ត្រីម្ដាយស្រែកហៅកូនឲ្យមកកាន់ផ្ទះ ៗលៗ )

៣ – ខ្យល់ព្យុះមកដល់ ទ្វេកម្លាំងជាលំដាប់ទាល់តែពេញទំហឹង ខ្យល់បក់បោកដូចម្ដេច? (កាន់គួបអ្វីៗស្ទើរតែចាំងអស់ ឲ្យតែប៉ះមុខ ហាក់ដូចជាខឹងក្រៃលែង) ភ្លៀងចាប់ធ្លាក់បែបណា ? (គ្រាប់ធំៗហើយក្រាស់ គេឃើញអ្វីនៅលើមេឃ ? (ផ្លេកបន្ទោររត់ខ្វាត់ខ្វែង ផ្គរលាន់រំពង រន្ទះបាញ់ម្ដងៗ នាំឲ្យក្មេងភ័យខ្លាំងឈប់ងូតទឹកភ្លៀង ) ៗ

៤ – ខ្យល់ព្យុះបង្អន់ល្បឿនបែបណា ? ( ខ្យល់កាន់តែថយកម្លាំងជាលំដាប់ ភ្លៀងឈប់ធ្លាក់ មេឃភ្លឺស្វាងឡើងព្រះអាទិត្យចាប់បញ្ចេញសូរ្យសែងជាថ្មី ) ៗ

៥ – ខ្យល់ព្យុះបណ្ដាលឲ្យមានហេតុដូចម្ដេចខ្លះ ? ( ចំពោះធាតុ

អាកាសៈ អាកាសបានត្រជាក់ គេដកដង្ហើមបានស្រួល ៗ ចំពោះមាគាំៈ ព្រោះខូចជាច្រើនអន្លើ ៗ ចំពោះរុក្ខជាតិៈ បាក់មែក ជ្រុះស្លឹក - ផ្កា - ផ្លែជាច្រើន ៗ ចំពោះផលដំណាំៈ ខូចខាតស្ទើរតែទាំងអស់ ៗ តើអ្នកមានមនោសញ្ចេតនាដូចម្ដេច នៅចំពោះមុខការអន្តរាយទាំងនេះ ?

## គោលសេចក្ដី

១– កាលៈទេសៈនឹងសញ្ញាឲ្យដឹងថាមានខ្យល់ព្យុះ ៗ

២– ដំណើរនៃខ្យល់ព្យុះៈ ខ្យល់-ផ្គរ-មនុស្ស-សត្វ ៗ

៣– ពេលដែលខ្យល់បក់ពេញទំហឹង (ត្រូវអធិប្បាយចំណែកនេះឲ្យច្រើនៈ ខ្យល់ - ភ្លៀង - ផ្លេកបន្ទោរ - រន្ទះ ផ្គរ)

៤– ពេលដែលខ្យល់បន្ថយល្បឿនៈ មេឃស្រឡះ ៗ

៥– ហេតុល្អនឹងហេតុអាក្រក់ដែលកើតឡើងពីខ្យល់ព្យុះ (គួរឲ្យអាសូរដល់កសិករនៅចំពោះមុខការអន្តរាយលើដំណាំ ដែលខ្លួនបានព្យាយាមថែរក្សាមកជាយូរខែមកហើយ !)

សេចក្ដីតែងទី ២– ចូរអ្នកធ្វើពិពណ៌នាអំពីអស្ដង្គតកាលនៅស្រុកស្រែ ៗ

## គោលសេចក្ដី

១– ព្រះអាទិត្យសន្សឹមចុះទៅកាន់ជើងមេឃ ៗ

២– ព្រះអាទិត្យលិច ៗ

៣– ពេលក្រោយព្រះអាទិត្យអស្ដង្គត ។

## សេចក្ដីអធិប្បាយ

១– គឺជាពេលល្ងាចថ្ងៃអាទិត្យមួយក្នុងខែឧសភា ។ នៅពេលដែលខ្ញុំបាទបានបំពេញកិច្ចការរួចហើយ ខ្ញុំបាទបានចាកចេញពីគេហដ្ឋានដើរទៅកាន់វាលស្រែដែលលាតល្វឹងល្វើយ នៅខាងក្រោយភូមិខ្ញុំបាទដើម្បីរំហើយប្រាណ ។

គាប់ជួនវេលានោះ ព្រះអាទិត្យកំពុងតែសន្សឹមទៅកាន់ជើងមេឃ បណ្ដាលកើតជាទេសភាពមួយគួរឲ្យទស្សនាពន់ពេក ។

នៅលើវាលស្រែ មានចំហាយខ្មៅព្រឿងៗ អណ្ដែតក្នុងលំហអាកាសមកក្រោមដណ្ដប់បំបាំងធម្មជាតិ ឲ្យងងឹតបន្តិចម្ដងៗ វាយោបក់រំភើយៗមកពីឯទិសនិរតីនាំធាតុត្រជាក់មកចាក់លើមុខនិងខ្លួនខ្ញុំបាទខ្លាន់ៗលើគ្នា ។ យូរៗ មានហ្វូងបក្សីហើរយ៉ាងលឿនសំដៅទៅឯគុម្ពឈើឯនាយ ។

២– មិនយូរប៉ុន្មានព្រះអាទិត្យចុះទៅដល់ជើងមេឃ ។ ក្នុងខណៈនោះ ផ្ទៃមេឃនៅខាងទិសបស្ចិមមានព័ណ៌ក្រហមឆ្អៅ ដោយកម្មរស្មីនៃព្រះអាទិត្យបញ្ចាំងពីក្រោមឡើងៗ ឯពពកសោតក៏ផ្គុំគ្នាកើតទៅរាងផ្សេងៗធំៗ គួរឲ្យស្ញើមពន់ពេក ខ្លះមានរាងដូចជាមនុស្សហាមាត់បគ្រន់

ខ្លះជាផ្កាអង្គុយ ខ្លះជាផ្សែងកំពុងមានកំពូលក្ដី ៗល។ តែភេទអស្ចារ្យនេះ ស្ថិតនៅពុំបានប៉ុន្មានទាំងក៏ត្រូវក្លាយពងហើយ រលាយបាត់ទៅដោយព្រះ ទិវាករលិចជ្រៅផុតបាត់ទៅ ៗ ខ្យល់ក៏កាន់តែរហើយត្រជាក់ឡើង មេឃ ក៏កាន់តែងងឹតទៅ យប់ក៏លាតសន្ធឹងម្លប់ងងឹតលើស្រុកភូមិ ៗ

៣– ពួកកសិករដឹកគោឬលីចបករណ៍ ដើរសំដៅទៅកាន់លំនៅ ដោយសន្ទនាជួងខ្មើយគ្នាលេងសើចក្អាកក្អាយ ៗ រទេះគោបញ្ចេញស្នូរ សព្ទគ្រលួចឥតអាក់ លាយនឹងសម្លេងក្មេងស្រែកច្រៀងក្ដែង ៗ ៗ ផ្ការនៅ ឯជាយភូមិចាប់ព្រះអស់តាំងអ៊ុស្សុង ៗ ដែលរាំហើញ ៗ ពន្លឺចង្កៀងលេច ចេញពីផ្ទះខ្លះហើយផ្កាយនានាក៏ចាប់បញ្ចេញរស្មីព្រិច ៗ ឯនភាល័យ ៗ បក្សីពត្រីបរចាកចេញពីទ្រនំហើរខ្វាត់ខ្វែង ខ្លះស្រែកឮគ្រលួចកណ្ដាល អាកាស ៗ

ខ្ញុំបានក៏ត្រឡប់មកគេហដ្ឋានវិញ ក្នុងចិត្តរីករាយ តែមានគំនិត រាយមាយទៅកាន់អាថ៌កំបាំងដែលនឹងកើតមានឡើងក្នុងពេលរាត្រីស្ងាត់ ៗ

---

ផ្នាក់អាទិកដ្ឋាន

តែងសេចក្ដី

ចូរតែងសេចក្ដីអធិប្បាយអំពីផ្សារនៅភូមិអ្នក ?

គំនូសតែង– នៅភូមិអ្នកមានផ្សារឬទេ ?

ទីកន្លែងផ្សារនោះសង់ដូចម្ដេច ។ គេមើលពីចម្ងាយឃើញដូចម្ដេច ដើរទៅជិតឮសូរអ្វី ? ។ មានមនុស្សច្រើននៅពេលណា ? ។ មនុស្សទាំងនោះទៅធ្វើអ្វីខ្លះ ។ ផ្សារមានប្រយោជន៍ដល់ស្រុកឬទេ ? បើគ្មានផ្សារគេទៅទិញឥវ៉ាណាឯណា ?

## សេចក្ដីអធិប្បាយ

នៅភូមិខ្ញុំមានផ្សារមួយ ផ្សារនោះសង់នៅទីដីវាលធំស្រឡះ គ្មានផ្ទាំងរាំងទេ គេមើលពីចម្ងាយទៅឃើញផ្សារនោះច្បាស់ណាស់ កាលណាដើរទៅជិតផ្សារ គេឃើញមនុស្សប្រុសស្រី ក្មេងចាស់ដើរចេញចូលប្រវាត់ជៀសគ្នាស្ទើរត្រូវ ហើយឮសូរសំឡេងជជែកគ្នាអឺងកង ។ ផ្សារនៅភូមិខ្ញុំមានមនុស្សច្រើនតែពេលព្រឹកទេ មនុស្សទាំងនោះខ្លះយករបស់ទៅលក់ ខ្លះទៅទិញយកមកធ្វើជាអាហារបរិភោគ ផ្សារមានប្រយោជន៍ដល់អ្នកស្រុកណាស់ បើគ្មានផ្សារគេមិនដឹងនឹងទៅទិញឥ-វ៉ាណាឯណាទេ ។

## តែងសេចក្ដីទី២

ចូរអ្នកអធិប្បាយអំពីផ្ទះចិនលក់ទំនិញមួយ ដែលអ្នកបានស្គាល់

ច្បាស់តើផ្ទះនោះសង់ដូចម្ដេច ? នៅក្នុងផ្ទះអ្នកឃើញមានទំនិញអ្វីខ្លះ ? រៀបចំបែបយ៉ាងណា ? ។ យោបល់របស់អ្នកយល់ឃើញដូចម្ដេច ?

## តែងសេចក្ដីទី ៣

ចូរអ្នកអធិប្បាយអំពីទីក្រុងណាមួយ ដែលអ្នកបានស្គាល់ច្បាស់ ? ទីក្រុងនោះនៅក្នុងឃុំ... ...ស្រុក... ខេត្តណា ? ធំឬតូច បណ្ដោយទទឹងប្រហែលប៉ុន្មានម៉ែត្រឬគីឡូម៉ែត្រ ? មានមន្ទីរអ្វីខ្លះ ? ។ នៅអមផ្លូវថ្នល់មានដើមឈើអ្វីខ្លះ ? ។ មានអ្វីជាលំអទីក្រុងនោះ (សួនផ្កា) ។ អ្នកស្រឡាញ់ទីក្រុងនោះឬទេ ពីព្រោះអ្វី ?

---

## ថ្នាក់បរិវឌ្ឍណាដ្ឋាន

## តែងសេចក្ដីទី ១

### អំពីដើមត្នោត និងប្រយោជន៍នៃត្នោត

ចូរឆ្លើយឲ្យប្រកបតាមពាក្យចោទខាងក្រោមនេះ

នៅស្រុកអ្នកមានដើមត្នោតឬទេ ?

ដើមត្នោតដូចដើមអ្វី ?

គេយកស្លឹកត្នោតទៅធ្វើអ្វី ?

គេយកជក់ត្នោតទៅធ្វើអ្វី ?

ដើមវាគេយកទៅធ្វើអ្វី ?

ទឹកត្នោតគេយកទៅធ្វើអ្វី ?

## សេចក្ដីឆ្លើយ

នៅស្រុកខ្ញុំមានដើមត្នោតដែរ ។

ដើមត្នោតដូចដើមដូងនិងដើមស្លា ។

គេយកស្លឹកត្នោតទៅប្រក់ផ្ទះ

ផក់ត្នោតគេយកទៅវេញខ្សែ ។

ដើមវាគេយកទៅធ្វើរនាបឬធ្វើទ ។

ទឹកត្នោតគេយកមកទទួលទានឬយកមកធ្វើស្ករ ។

## ផ្នែកសេចក្ដីទី ២

### អំពីអំពៅ

ចូរឆ្លើយតាមពាក្យចោទខាងក្រោមនេះ

នៅស្រុកអ្នកមានគេដាំដើមអំពៅឬទេ ។ ដើមអំពៅដូចដើមអ្វី? ដើមអំពៅមានកំពស់ប្រហែលប៉ុន្មានម៉ែត្រ គេដាំអំពៅប្រយោជន៍អ្វី ?

## ផ្នែកសេចក្ដីទី ៣

ចូរអធិប្បាយអំពីការធ្វើប្រេងដូងតាមពាក្យចោទខាងក្រោមនេះ ។

អ្នកដែលឃើញគេធ្វើប្រេងដូងឬទេ ? គេយកសាច់ដូងខ្ចីឬសាច់ដូងទុំមកធ្វើប្រេង ? គេយកសាច់ដូងទុំមកធ្វើដូចម្ដេចខ្លះទើបកើតទៅជាប្រេង ។

## អាជិកដ្ឋាន

## នព្វន្ត

**មេរៀនទី១.– លេខគុណនឹង ១០. ១០០- ១.០០០**

សៀវភៅមួយមាន ១៦ សន្លឹក ។ តើសៀវភៅ ១០ ។ សៀវភៅ ១០០ សៀវភៅ ១.០០០ មានប៉ុន្មានសន្លឹក ។

ដើម្បីនឹងរកចំនួនសន្លឹកដែលមាននៅក្នុងសៀវភៅ ១០ សៀវភៅ ១០០ សៀវភៅ ១.០០០ ត្រូវយកចំនួនសន្លឹកគុណនឹងសៀវភៅ ១០ ។ ១០០ ។ ១.០០០, គឺ ១៦ស × ១០; ១៦ស × ១០០; ១៦ស × ១.០០០ ;

សេចក្ដីសំខាន់.–ដើម្បីនឹងគុណចំនួនណានឹង១០ ។ ១០០ ។ ១.០០០ បើមិនបាច់ធ្វើលេខគុណទេ គេគ្រាន់តែថែមនៅស្ដាំចំនួននោះ សូន្យមួយបើគុណនឹង ១០ ។ សូន្យពីរ បើគុណនឹង ១០០ ។ សូន្យ

បីបើគុណនឹង ១.០០០ ។ល។ ១៦ × ១០ = ១៦០ -
១៦ × ១០០ = ១.៦០០; - ១៦ × ១.០០០ = ១៦.០០០

វិធីគិតមាត់ទទេ.- ត្រូវជាប៉ុន្មាន :

ផ្លែស្វាយ ៣ ដប់ដង ។ ផ្លែពុទ្រា ៤ ដប់ដង ។ ផ្លែដូង ២៥ ដប់ដង ។

សំពត់ ១ម៉ែត្រថ្លៃ ១៥រ, តើសំពត់ ១០ម ថ្លៃប៉ុន្មាន ។ ១០០ម ។ ១.០០០ម

គោញី ១ ថ្លៃ ២៥០រ តើគោញី ១០០ ថ្លៃប៉ុន្មាន ។

ក្នុង ១ ថ្ងៃម្ដាយខ្ញុំសន្សំបាន ៧៥រ តើក្នុង ១.០០០ ថ្ងៃគាត់សន្សំបាន ប៉ុន្មានរៀល ។

វិធីហាត់សរសេរ - ១ -- ចូរធ្វើលេខខាងក្រោមនេះ :

១៤រ × ១០ = ៦៥ល × ១០០ = ២៣ល × ១០០០ = ៥ × = ៥០ស

២៥រ × ១០ = ៣៦ល × ១០០ = ៤៥ប × ១០០០ = ៣៤រ = ៣៤០

៧ × ១០ = ៩ល × ១០០ = ៥៧ស × ១០០០ = ៨រ × ... = ៨០០រ

មេរៀនទី ២. លេខគុណថែមការគត់

១០ ១០០ ១០០០

ដងប៉ាកា ១ ថ្លៃ ៣រ៥០ តើដងប៉ាកា ១០ ១០០ ១០០០ ថ្លៃប៉ុន្មាន ? ។

ដើម្បីនឹងរកថ្លៃដងប៉ាកា ១០ - ១០០ - ១០០០ ត្រូវយកថ្លៃដងប៉ាកា មួយគុណនឹងចំនួនដងប៉ាកា ១០ - ១០០ - ១០០០ គឺ ៣រ៥០ × ១០ = ៣រ៥០ × ១០០ = ៣រ៥០ × ១០០ = ។

សេចក្ដីសំខាន់ ៖— ដើម្បីនឹងគុណរកចំនួនបែងភាគភាយ ១០-១០០-១០០០ គេត្រូវរំកិលកណ្ដាក់សញ្ញាទៅខាងស្ដាំមួយខ្ទង់បើគុណនឹង ១០ - ពីរខ្ទង់បើគុណនឹង ១០០ បីខ្ទង់បើគុណនឹង ១០០០ ។

ឧបមា ៣,៥០ × ១០= ៣៥,០០ ។ ៣,៥០ × ១០០= ៣៥០, ។ ៣,៥០ × ១០០០ = ៣៥០០,០០

វិធីហាត់មាត់ទទេ ៖— ត្រូវជាប៉ុន្មាន

គុណនឹង ១០: ៥,៦២; ៣០ម ៤; ៥០លី ៨១; ២៥-៧០ ។

គុណនឹង ១០០: ៣១,៧០; ៤ម,០៨៣; ០លី ៩៣៧; ២១ម,០០៦ ។

គុណនឹង ១០០០: ០,៥៨; ៥ម ៤០៨; ៣លី ,០០៦; ២៥,០៧ ។

សៀវភៅមួយថ្លៃ ១,៥៥ តើសៀវភៅ ១០០ ថ្លៃប៉ុន្មាន ។

ស្ករមួយគីឡូក្រាមថ្លៃ ១១,៨៥ តើ ១០ គីឡូក្រាមថ្លៃប៉ុន្មាន ។

ខ្សែលួសមួយម៉ែត្រថ្លៃ ០,៩៨ តើ ១០០០ ម៉ែត្រថ្លៃប៉ុន្មាន ។

វិធីហាត់សរសេរ បំណោទ

ជាងដេរសំលៀកបំពាក់ម្នាក់ទិញសំពត់ជាឌុបចំនួន ១០០០ ម៉ែត្រ ថ្លៃក្នុង ១ ម៉ែ ១៤-០៨ ហើយនិងសំពត់សាក្លាតចំនួន ១០ ម៉ែ ថ្លៃ ៨៥- ក្នុង ១ ម៉ែត្រ ។ តើគេថែមមកវិញប៉ុន្មាន បើជាងនោះឲ្យក្រដាសប្រាក់ ១០០រ ចំនួន ៧ សន្លឹកទៅអ្នកលក់សំពត់ ។

## មេរៀនទី ៣ — លេខគុណនៃចំនួនបែងភាគគត់

| | |
|---|---|
| ២៥៨ | ២០.៣២ |
| × ៤១៣ | × ២.៥១ |
| ៧៧៤ | ២០៣២ |
| ២៥៨ | ១០១៦០ |
| ១០៣២ | ៤០៦៤ |
| ១០៦៥.៥៤ | ៥១.០០៣២ |

ដើម្បីធ្វើលេខគុណចំនួនភាគគត់ៈ ទី ១— គេសរសេរចំនួនលេខទាំងពីរនោះមួយលើមួយក្រោម ហើយគុណដូចជាចំនួនដុំដែរតែ មានអារម្មណ៍នឹងគណកសញ្ញាឡើយ ។ ទី ២.— គេត្រូវដាក់សញ្ញានៅខាងស្តាំល័ក្ខតាមចំនួនលេខបែងភាគដែលមាននៅក្នុងចំនួនដំណាំងនៃមេគុណ ។

វិធីហាត់មាត់ទទេ ·— ខ្សែលួសមួយបង្វាយមាន ១២ម៉ ៣០ តើខ្សែលួស ៥ បង្វាយមានប៉ុន្មានម៉ែត្រ ។

អង្ករមួយកំប៉ុងថ្លៃ ២៛ ១៥ តើ ៤ កំប៉ុងថ្លៃប៉ុន្មាន ។ សំពត់មួយម៉ែត្រថ្លៃ ១៣៛ ២០ តើសំពត់ ៣ម៉ ៥០ ថ្លៃប៉ុន្មាន ។ មៀមួយគីឡូក្រាមថ្លៃ ០៛ ៣៥ តើ ៣ គ.ក្រ ៧៤ ថ្លៃប៉ុន្មាន ។

វិធីហាត់សរសេរ.— ចូរធ្វើលេខខាងក្រោមនេះ :

២៥៨ × ១៤៣ = ៤៥៧ × ២,៤៨ = ១២០,៣០ × ១៣,៣០ =

៨៨,០៤ × ២,៤ = ៦៥២ × ០,៣៥១ = ១២៨៩,១៣ × ១៥១៣ =

ចំណោទ.— ជាងការឈើ១៨នាក់ធ្វើការក្នុងរោងការឈើ ក្នុង ១ ថ្ងៃម្នាក់ ៗ បានឈ្នួល០រ៧៥ ជាងការទាំងអស់នោះធ្វើការ ៣១២ ថ្ងៃ ក្នុង១ឆ្នាំតើប្រាក់ឈ្នួលជាងការឈើប៉ុន្មានក្នុង១ឆ្នាំ ?

## រង្វាស់រង្វាល់

មេរៀនទី១.— សូមយកផ្ទាំងគំនូររង្វាស់រង្វាល់ដែលមានរូបិយវត្ថុគឺ ហ្វ្រង់-សង់ទីម ។ល។ មកបង្ហាញសិស្សឲ្យឃើញជាក់ច្បាស់ រួចហើយ ប្រាប់ថានៅប្រទេសយើង គេចាយប្រាក់រៀល ។ ក្នុងនគរនីមួយៗមាន ប្រាក់សំរាប់ចាយផ្សេងៗពីគ្នា ដូចប្រាក់រៀលចាយសព្វថ្ងៃនេះ មិនមែន ដូចប្រាក់ដែលគេចាយនៅនគរសៀមទេ ។ ឯចំណែកនៅស្រុកបារាំង សែសនឹងចេញឲ្យថ្លៃទំនិញដែលគេទិញនោះត្រូវឲ្យជាហ្វ្រង់ៗ ហ្វ្រង់នេះគឺ មេរូបិយវត្ថុ នៅនគរបារាំងសែស គេសសេរកាត់ . ហ្វ្រ ។ បួនណាមាន មនុស្សនៅនគរយើងនេះ ទិញទំនិញនៅស្រុកបារាំងសែស មនុស្សនោះ ត្រូវចេញថ្លៃជាចំនួនហ្វ្រង់ ដើម្បីឲ្យបានប្រាក់ហ្វ្រង់នោះគេត្រូវប្តូរប្រាក់ រៀលយើងនឹងប្រាក់ហ្វ្រង់ សព្វថ្ងៃនេះកាលណាគេយកប្រាក់១រៀលទៅ គេដូរបានជា១៧ហ្វ្រង់ ហេតុនេះគេដឹងថាក្នុង១រៀលយើងមានដម្លៃ ១៧

ហ្វ្រង់ ។ ឯការប្តូរគ្នាបានតែនៅផ្ទះបង់ការប្រាក់ ឬនៅផ្ទះខ្សែលួស បើគេដើរទៅទិញទំនិញនៅស្រុកបារាំងសែសកាត់យកពីហ្វ្រង់ គឺសង់ទីម នៅកន្លែងចំនួនហ្វ្រង់សង់ទីម ត្រូវសរសេរនៅខ្ទង់ ទី ២ ខាងស្តាំគណ្តក់សញ្ញា ។

វិធីយាត់ភាត់ធនេ.— កន្លះហ្វ្រង់ ត្រូវជាប៉ុន្មានសង់ទីម មួយហ្វ្រង់ត្រូវជាប៉ុន្មានសង់ទីម ។ ៣ហ្វ្រង់កន្លះ ត្រូវជាប៉ុន្មានសង់ទីម ។ ១២ហ្វ្រង់ត្រូវជាប៉ុន្មានសង់ទីម ។ល។ ១០០សង់ទីមត្រូវជាប៉ុន្មានហ្វ្រង់ ។ ៤០០សង់ទីមត្រូវជាប៉ុន្មានហ្វ្រង់ ។ ៦៧០សង់ទីមត្រូវជាប៉ុន្មានហ្វ្រង់ ។ ដម្លៃប្រាក់រៀល គឺ ១៧ហ្វ្រង់ ប្តូរគិតជាហ្វ្រង់ត្រូវបានប៉ុន្មាន បើប្រាក់៦៛ ។ ៨៛ ។ ១៣៛ ។ ៥០៛ ។ល។ ដម្លៃប្រាក់រៀល គឺ ១៧ហ្វ្រង់ ត្រូវបានប៉ុន្មានបើ២០ហ្វ្រង់ ។ ១៥ហ្វ្រង់ ។ ៦៧ហ្វ្រង់ ។ ៥៥ហ្វ្រង់ ។ ៣៥០ហ្វ្រង់ ។ ៤៨០ហ្វ្រង់ ។

ចំណោទ.— ១ —នៅផ្ទះលក់សៀវភៅមួយ គេទិញសៀវភៅមើល ២០០ថ្លៃ៨ហ្វ្រង់មួយ និងសៀវភៅមើលមួយទៀតថ្លៃ១៨ហ្វ្រង់ ។ បើដម្លៃប្រាក់រៀល២០ហ្វ្រង់ ខ្ញុំត្រូវឲ្យប៉ុន្មានរៀលទៅអ្នកលក់សៀវភៅនោះ ។

២.— ក្នុងហាងបារាំងមួយមានត្រែឈើមួយគេដាក់ថ្លៃ ៧០៛ ត្រែដែកមួយ ១៨០០ហ្វ្រង់ ដម្លៃប្រាក់ ១៧ហ្វ្រង់ តើត្រែណាថ្លៃជាងគេ ។

មេរៀន ទី ២.– រៀនសាអំពីរង្វាស់បណ្តោយ : ម៉ែត្រនិងដេកាម៉ែត្រ សូមតែងធ្វើឲ្យគ្រប់សេចក្តីផ្សេងៗ ដូចខែមុនៗមក ។

មេរៀនទី ៣.– រៀនសាពីហិកតូម៉ែត្រនិងគីឡូម៉ែត្រ

មេរៀនទី ៤.– រៀនសាអំពី ដេស៊ីម៉ែត្រ – សង់ទីម៉ែត្រ, មិលីម៉ែត្រ ។

---

បរិច្ឆណាដ្ឋាន

**នព្វន្ត**

ក្នុងខែនេះគ្រូសាបង្រៀន របៀបធ្វើលេខចំនួនដុំតាំង៤បែប និង របៀបគុណ-ចែកចំនួនបង្កិភាគនឹង១០នឹង១០០ ។

មេរៀនទី១.– សាបញ្ញាក់អំពីលេខបូកនឹងលេខសងចំនួនដុំ ៗ

របៀបបង្រៀន·

១.– ការហាត់គិតដោយប្រាជ្ញា - រៀនបន្ថែម ៥, ៦, ៧, ៨, ៩, លើចំនួនមួយ – រៀនបន្ថយ ៥, ៦, ៧, ៨, ៩, ពីចំនួនមួយដូចជា ៖ ៣៧៛ + ៥៛ : ។ នាំសិស្សថា ៖ ៧នឹង៥ត្រូវជា១២ ។ ៣០នឹង១២ ត្រូវជា៤២ ។ ៩៣៛ – ៧៛ = នាំសិស្សរៀនគិតថា ៖ ៩០ដក.៧នៅសល់

៨៣ ។ ៨៣ និង ៣ ត្រូវជា ៨៦ ។ នាំសិស្សហាត់គិតបែបខាងលើនេះ ឲ្យបានច្រើនបំផុត ។

២- ការបញ្ជាក់អំពីលេខបូកនិងលេខសង

ក- អាវ ១ ថ្លៃ ១៣៥៛ ខោ ១ ថ្លៃ ៨៧៛ ។ តើខោនិងអាវត្រូវជាថ្លៃប៉ុន្មាន?

ខ- គោនិងសេះថ្លៃ ៧៤២៛ បើគោថ្លៃ ៣៥៧៛ តើសេះនោះត្រូវជាថ្លៃប៉ុន្មាន ។

ឲ្យសិស្សធ្វើលេខបូក, លេខសងខាងលើនេះ នៅលើក្តារខៀន ហើយពន្យល់បន្ថែមត្រង់ណាដែលពិនិត្យឃើញថា សិស្សពុំទាន់យល់ច្បាស់ ។

៣- ការហាត់បញ្ជាក់នៅលើក្តារខៀន

២៤៧៛ + ៣៥៩៛ = ។ ១៧៩៛ + ៤៥៦៛ =

៥៣៧៛ - ១៤៥៛ = ។ ៧៥៣៛ - ២៤៧៛ =

៤- ការហាត់សរសេរនៅក្នុងសៀវភៅ

ចូរធ្វើលេខខាងក្រោមនេះ៖

១៦៥៛ + ៣៥៣៛ =

២៤៦៛ + ១៧៤៛ =

៥២៧៛ + ២៤៣៛ =

៤៨១៛ + ១៥៧៛ =

ចំណោទ:– ឪពុកខ្ញុំគាត់លក់គោ១បានប្រាក់៣៥៧៛ លក់ក្របី១ បានប្រាក់២៧៣៛ ហើយគាត់យកប្រាក់នោះទៅទិញសេះមួយថ្លៃ ៤៧៥៛ ។ តើគាត់ត្រូវនៅសល់ប្រាក់ប៉ុន្មានរៀលទៀត ។

មេរៀនទី២.– សាបញ្ជាក់អំពីលេខគុណនឹងលេខចែកចំនួនដុំនឹងចំនួនមានលេខតែមួយគត់ ។ សូមធ្វើតាមរបៀបខាងលើនេះ ហើយសូមតែងការហាត់ឲ្យសព្វគ្រប់ផង ។

មេរៀនទី៣ – សាបញ្ជាក់អំពីលេខ បូក-សង-គុណ-ចែក ចំនួនបែងភាគគត់ ។

សូមធ្វើតាមរបៀបខាងលើនេះឲ្យសព្វគ្រប់ផងចុះ

មេរៀនទី ៤.– រៀនគុណចំនួនបែងភាគនឹង១០នឹង១០០ ។

## របៀបបង្រៀន:

ការហាត់គិតដោយប្រាជ្ញា

១៥៛ × ១០ = ។ ៧៛ × ១០០ = ។ ៤៧៛ × ១០៛ = ។

៧៛ × ១០០ = ។ ៥៩៛ × ១០ = ។ ៩៛ × ១០ = ។

២.- រៀនគុណចំនួនបែងភាគនឹង១០នឹង១០០ ។ ធ្វើលេខឲ្យសិស្សធ្វើលេខនេះនៅលើក្ដារខៀន ៖

| | |
|---|---|
| ២៛៥៣ | ៥៛១៥៧ |
| × ១០ | × ១០០ |
| ២៥៛៣០ | ៥១៥៛៧០០ |

នាំសិស្សពិនិត្យមើលចំនួន ២៛៥៣ នឹង ២៥៛៣ ។ ៥ម ១៥៧ នឹង ៥១៥ម ៧ តើកណ្ដកសញ្ញាចិតទៅខាងណាចំនួនប៉ុន្មានខ្ទង់ ? ។

៣.– ការហាត់បញ្ជាក់នៅលើក្ដារខៀន

៥៛៤៧ × ១០ = ។ ៧ម ៣៥៦ × ១០០ = ។

២ម ៥៧២ × ១០ = ។ ១៩ម ១៥០ × ១០០ = ។

៤. ការហាត់សរសេរនៅក្នុងសៀវភៅ.–

ក– ចូរធ្វើលេខគុណខាងក្រោមនេះ ៖

៤៛៧៩ × ១០ =... ។ ៩ម ៤៦៨ × ១០០ =... ។

១៧៛៥០ × ១០ =... ។ ៧៛៧៤ × ១០០ =... ។

ខ– ចំណោទ. ម្ដាយខ្ញុំគាត់មានប្រាក់៣៧០៛ គាត់ទៅផ្សារទិញសំពត់ ១០ម ថ្លៃ ៩៛៤៣ ក្នុង ១ម ។ តើគាត់ត្រូវនៅសល់ប្រាក់ប៉ុន្មាន ? ។

មេរៀនទី៥.– ចែកចំនួនបែងភាគនឹង ១០ នឹង ១០០

សូមធ្វើតាមរបៀបគុណលេខចំនួនបែងភាគនឹង ១០ នឹង ១០០ ខាងលើនេះ ហើយសូមតែងការហាត់ឲ្យសព្វគ្រប់ផង ។

មេរៀនទី៦.– សាបង្រៀនឡើងវិញ

សាបង្រៀនអំពីការដែលបានបង្រៀនក្នុងខែនេះ សូមមើលតាមរបៀបរៀបចំបង្រៀនខាងលើស្រាប់ ។

## រង្វាស់រង្វាល់

មេរៀនទី១.– អំពីកូនទម្ងន់មួយគីឡូក្រាម

របស់សម្រាប់បង្រៀន.– កូនទម្ងន់១គក្រ–២គក្រ របស់ដែលមានទម្ងន់ ១គក្រ-២គក្រ–៣គក្រ ៥គក្រ ។

### របៀបបង្រៀន – ១គ្រូបង្ហាញកូនទម្ងន់១គក្រ

ជាឈ្មោះទម្ងន់នោះឱ្យសិស្សស្តាប់ហើយសរសេរជាអក្សរ ទឹងជាអក្សរកាត់នៅលើក្តារខៀនឱ្យសិស្សមើល ហើយនាំសិស្សពិនិត្យមើលកូនទម្ងន់នោះ រូបកង់ពណ៌-ជាតិ អក្សរដែលមាននៅលើកូនទម្ងន់នោះ៖– គង់ដែលសម្រាប់កាន់ យកទឹងប្រហោងខាងបាត

២.– នាំសិស្សពិនិត្យទម្ងន់១គក្រ – ដោយលើកស្ទាបមើលឱ្យបានច្រើនគ្នាបំផុតឱ្យបានស្គាល់ទម្ងន់ ១ គក្រច្បាស់ ។

៣.– ការហាត់ស្ទាបទម្ងន់ ឱ្យសិស្សស្ទាបទម្ងន់របស់អ្វីមួយដែលលោកគ្រូដឹងច្បាស់ថាមានទម្ងន់១ គក្រ ហើយឱ្យស្ទាបទម្ងន់របស់ឯទៀតដែលមានទម្ងន់ ២ គក្រ-៣ គក្រ ។

៤.– ការហាត់បញ្ជាក់.– មាន ១០ ទម្ងន់ ២០ គក្រតើមាន ១ ទម្ងន់ប៉ុន្មាន ? មាន៥ ទម្ងន់ប៉ុន្មាន ?

ស្ករ ១ គក្រថ្លៃ ៥៛ បើគេមានប្រាក់ ២០៛ គេទិញបានស្ករ ប៉ុន្មានគក្រ ?

### ៥ - ការហាត់សរសេរនៅក្នុងសៀវភៅ

ចំណោទ.- ម្តាយខ្ញុំគាត់មានប្រាក់១២០៛ គាត់ទិញសំពត់១០ម ថ្លៃ ៨៛៥០ក្នុង១ម សល់អំពីនោះគាត់ទិញស្ករសថ្លៃ ៥៛ក្នុង ១គក្រ ។ តើគាត់ត្រូវបានស្ករប៉ុន្មានគក្រ ។

មេរៀនទី ២- កូនទម្ងន់គីឡូក្រាមនិងជញ្ជីង-ការរៀនថ្លឹង ។ ត្រូវមានជញ្ជីងកូនទម្ងន់ ១ គក្រ– ២ គក្រ– ៥ គក្រ និងរបស់សម្រាប់ថ្លឹង ។ សូមធ្វើតាមរបៀបខាងលើនេះ ប៉ុន្តែសូមបង្វឹកសិស្សឲ្យរៀនថ្លឹង របស់ឲ្យបានច្រើនផង ។

មេរៀនទី ៣ អំពីគីឡូម៉ែត្រ ។

វត្ថុនេះគ្មានរូបជាប្រធានទេ មានតែឈ្មោះគ្រាន់តែសំគាល់ឲ្យដឹងថា ១០០០ម ឬ១០០ដាម១០ហម. ត្រូវជា ១ គីឡូម៉ែត្រ ។ វត្ថុនេះសម្រាប់វាស់ព្រំប្រទល់នគរ – វាស់បណ្តោយផ្លូវថ្នល់ជាដើម ។

មេរៀនទី ៤- អំពីការរៀនស្ទានចម្ងាយជាគីឡូម៉ែត្រ នាំសិស្សរៀនស្ទានចម្ងាយពីសាលារៀនទៅកន្លែងមួយ ដែលមានចម្ងាយ ៣,៤,៥ គ.ម ។ ចម្ងាយពីកន្លែងមួយទៅកន្លែងមួយទៀតដែលគេមាន

កត់សំគាល់ទៅគោលតាមថ្ងៃថ្លល់ ។ សូមតែងការហាត់សព្វគ្រប់តាមរបៀបខាងលើនេះឲ្យស្រួលផង ។

---

## កុមារដ្ឋាន

### គណិត

ក្នុងខែនេះត្រូវសាបច្រៀនអំពីចំនួន ដែលសិស្សបានរៀនរួចហើយ គឺសាបញ្ជាក់អំពីចំនួនពី១ដល់ ១០០ អំពីលេខបូកនឹងលេខសងត់គ្រា ទុកមានគ្រាទុក គុណនឹងចែកចំនួននឹងពីរ បី បួន ។

មេរៀនទី ១.– សាបញ្ជាក់ អំពីចំនួន ពី១ដល់១០០ ។

ការរៀនផ្សំ – រៀន – មើល – រៀនសរសេរចំនួន ។

របស់សំរាប់បង្រៀន – ចង្កើះបាច់ ចង្កើះរាយ – លុយសេនប្រាក់កាក់១០សេន ។

របៀបបង្រៀន–

១-មតិសំខាន់–ឲ្យសិស្សរាប់របស់បន្ថែមពីរៗបីៗបួនៗពី១ដល់ ១០០ រាប់បន្ថយពី១០០មកវិញ ។

២– រៀនផ្សំចំនួន.– គ្រូផ្សំចង្កឹះឬប្រាក់កាក់និងលុយជាចំនួនឲ្យសិស្សថាចំនួនឬគ្រូថាចំនួនឲ្យសិស្សផ្សំ (១៤-២៣-៣៥-៤១-៥៧-៩៣-៧២-៨៦......) ។

៣–ការរៀនអានចំនួន– គ្រូបង្អុលចំនួនដែលសរសេរនៅលើក្តារខៀនឬឲ្យសិស្សម្នាក់ថាឲ្យសិស្សម្នាក់ទៀតបង្អុលឬឲ្យសិស្សម្នាក់បង្អុលឲ្យសិស្សម្នាក់ទៀតថា ។

៤- ការហាត់សរសេរចំនួន.– គ្រូថាចំនួនឲ្យសិស្សសរសេរនៅលើក្តារឆ្នួន តាមរបៀប "ឡាម៉ាទីនីញែរ" ។

៥-ការហាត់សរសេរនៅក្នុងសៀវភៅ.– សូមគ្រូតែងការហាត់នេះដាក់ឲ្យសិស្សធ្វើតាមកំរិតសិស្សផង ។

មេរៀនទី២,– ចំនួនដល់ ១០០

រៀនធ្វើលេខបូកមានត្រាទុក ។

របៀបបង្រៀន

១មតិសំខ្យា-ឲ្យសិស្សរាប់បន្ថែម២-៣-៤ពី១ដល់១០០ ។

២–ពន្យល់របៀបធ្វើលេខបូកមានត្រាទុក (សិស្សម្នាក់កាន់ចង្កឹះ ៣៥ សិស្សម្នាក់ទៀតកាន់ចង្កឹះ ២៧ តើសិស្សទាំងពីរនាក់មានចង្កឹះប៉ុន្មាន) គ្រូធ្វើលេខបូក ៣៥ + ២៧នេះនៅលើក្តារខៀនជាមួយសិស្សថាៈ ៥និង៧ត្រូវជា១២. ខ្ញុំសរសេរចំនួនលេខ២ ខ្ញុំត្រាចំនួន១នៅខ្ទង់ដប់ ទុក

ដើម្បីនឹងយកទៅបន្ថែមនឹងខ្ទង់ដប់ ឲ្យថា១នឹងបីត្រូវជាបួន ៤នឹង២ត្រូវជា៦ ឲ្យសរសេរចំនួនដប់នេះនៅក្រោមចំនួនដប់ ឃើញ៦២ ។

៣ – ការហាត់បញ្ជាក់នៅលើក្ដារខៀន៖ ១៦+៤៩ = ។

៣៩+២៤ = ។ ៤៧+២៣ ។ ៥៤+២៨ = ។

៤ – ការហាត់បញ្ជាក់នៅលើក្ដារឆ្នួន៖ ២៣+៣៩ = ។

១៧+៤៦ = ។ ៣៥+៤៧ = ។ ២៤+៤៩ = ។

៥ – ការហាត់សរសេរនៅក្នុងសៀវភៅ

(សូមតែងការហាត់ឲ្យសិស្សធ្វើនៅក្នុងសៀវភៅផង)

មេរៀនទី៣ .– ចំនួនដល់១០០

រៀនធ្វើលេខសងមានត្រាទុក ។

មេរៀនទី ៤.– ចំនួនដល់១០០

រៀនគុណចំនួននឹង ៤ ។

មេរៀនទី៥.– ចំនួនដល់១០០

រៀនចែកចំនួនជា ៤ ។

រង្វាស់រង្វាល់

ក្នុងខែនេះត្រូវសាបង្រៀនអំពីវិជ្ជា ដែលបានបង្រៀន តាំងពីដើមមក សូមរើសវិជ្ជាដែលបានបង្រៀនរួចហើយ នោះយកមកបង្រៀនម្តងពន្យល់ ថែមទៀតត្រង់កន្លែងដែលពិនិត្យឃើញថាសិស្សពុំទាន់យល់ច្បាស់ ។

សូមមើលតាមរបៀបរៀបចំក្នុងទស្សនាវដ្ដីខែមុន ៗ ដែលមានសព្វគ្រប់ស្រាប់ ។

---

អាទិកាដ្ឋាន

## វត្ថុស្វាធ្យាយន៍

អាទិត្យទី១–. ស្តាំ – ឆ្វេង

សុំមើលមេរៀនក្នុងសៀវភៅវត្ថុស្វាធ្យាយន៍ សំរាប់បរិវច្ចណដ្ឋាន ទំព័រទី ១០៤ , ១០៥ និង ១០៦

អាទិត្យទី២–. ប្រៃសណីយ៍ទូរលេខ

ទូរសព្ទមានខ្សែនិងទូរសព្ទឥតខ្សែ

មេរៀនសង្ខេប គេផ្ញើដំណឹងកាន់គ្នាទៅវិញទៅមកដោយ សំបុត្រឬដោយទូរលេខឬទូរសព្ទ ។

ដើម្បីនឹងផ្ញើសំបុត្រគេត្រូវបិតតែមតាមកំណត់ច្បាប់ហើយយកសំបុត្រនោះទៅដាក់ក្នុងប្រអប់សំរាប់ទទួលសំបុត្រនៅឯមន្ទីរប្រៃសនីយ៍ ។

នៅមន្ទីរនោះភ្នាក់ងារប្រៃសនីយ៍ចាត់ផ្ញើសំបុត្រនានាទៅឲ្យអ្នកទទួលដល់ទីកន្លែងតាមអស័យដ្ឋាន ( ម.ថ=អាស័យ·យ៉ាត់-ដ្ឋាន: (Adresse) ដោយរថយន្ត, រថភ្លើង, យន្តហោះឬដោយកប៉ាល់ ។

( សុំគ្រូយកស្រោមសំបុត្រមួយមកបង្ហាញសិស្ស ហើយបង្ហាញរបៀបការខ្ទ៍នឹងរបៀបបិតតែម )

ទូរលេខជាគ្រឿងមួយបែបសំរាប់ផ្ញើដំណឹងបានយ៉ាងឆាប់ទាន់ចិត្ត ។ គ្រឿងនេះដើរដោយកម្លាំងអគ្គីសនី ហើយភ្ជាប់ពីកន្លែងមួយទៅកន្លែងមួយដោយខ្សែលួសធ្វើពីលោហធាតុ ។ ជូនគេបង្កប់ខ្សែលួសនេះតាមបាតសមុទ្រឬទន្លេក៏មាន ។ ក្នុងការប្រើគ្រឿងនេះគេសន្មត់ប្រើគំនូសព្យញ្ជនៈនានា ។

ឧទាហរណ៍ A=. -;B=. — . .,C · - ,

ទូរសព្ទមានខ្សែគឺគ្រឿងសំរាប់និយាយការគ្នាដោយប្រើកម្លាំងអគ្គីសនីដែរ ។ គេភ្ជាប់គ្រឿងនេះពីកន្លែងមួយទៅកន្លែងមួយដោយខ្សែលួសធ្វើពីលោហធាតុដែរ ។

ឯទូរសព្ទឥតខ្សែគឺជាគ្រឿងសំរាប់ផ្ញើសព្ទឬសញ្ញា ដែលគេសន្មត់

ប្រើតាមលំហអាកាសដោយឥតចាំបាច់ប្រើខ្សែឡើយ ។

## អាទិត្យទី ៣. ម៉ាស៊ីនដើរដោយកម្លាំងបំហាយទឹក

ទឹកពុះក្នុងកំសៀវគោចក្ដៅឲ្យគំរបកំសៀវបើកបានមកពីកម្លាំងចំហាយទឹក ។ បើកាលណាគេយកបំពង់ដែកមួយមកដាក់ទឹកពាក់កណ្ដាលហើយចុកឲ្យជិតរួចយកទៅកំដៅភ្លើង មិនយូរប៉ុន្មានទឹកនឹងពុះ បន្ទាប់មកគេនឹងឃើញឆ្នុកនោះខ្ទាតចេញជាពុំខានដោយសារចំហាយទឹកដាក់ ៗ គឺកម្លាំងចំហាយនេះហើយដែលនាំឲ្យម៉ាស៊ីនកប៉ាល់, ម៉ាស៊ីនរថភ្លើង, ម៉ាស៊ីនកិនស្រូវ.......បើកបរបាន ។ តែដើម្បីនឹងឲ្យទឹកពុះមានចំហាយ គេត្រូវដុតធ្យូងឲ្យមានកំដៅខ្លាំង ៗ ដូច្នេះសម្រេចទៅគឺភ្លើងធ្យូងនេះ ដែលជាហេតុនាំឲ្យគ្រឿងម៉ាស៊ីនកប៉ាល់ឬរថភ្លើងដើរបាន ។

## អាទិត្យទី ៤.– របៀយគ្គឹងយន្តហោះ

ម៉ាស៊ីនចំពូកនេះមិនដើរដោយកម្លាំងចំហាយទឹកពុះឡើង ៗ គេដឹងថាគ្រោះថ្នាក់នឹងមានជាប្រាកដដល់ជនណាដែលកាន់ចង្កៀងប្ដូចនុះ ដែលកំពុងឆេះមានអណ្ដាតចូលទៅក្នុងកន្លែងណាមួយ ដែលមានចំហាយប្រេងសាំងព្រោះចំហាយប្រេងសាំងនឹងខ្យល់លាយគ្នាតែកាលណាមកប៉ះអណ្ដាតភ្លើងនឹងឆេះហើយផ្ទុះផង ៗ

អ្នកប្រើចង្កៀងដុតស្រាចាស់ពេកឬខូចក៏មានគ្រោះថ្នាក់ដែរ ពីព្រោះចំហាយស្រាដុតលាយនឹងខ្យល់ តែប៉ះនឹងអណ្ដាតភ្លើងក៏ឆេះហើយផ្ទុះដែរ ។

គឺកម្លាំងដែលប្រេងសាំងនឹងខ្យល់ឆេះផ្ទុះនេះហើយ ដែលជាហេតុនាំឲ្យម៉ាស៊ីនរថយន្តនឹងម៉ាស៊ីនយន្តហោះដើរបាន ។

---

## អធិកដ្ឋាន

## វិធីបង្ការរោគ

### អាទិត្យទី ១.– ជំងឺនៅក្នុងពោះវៀន – គ្រុន

គោលសេចក្ដី ១.– លក្ខណៈគ្រុនធម្មតា – គឺជាជន្ទ្រខ្លួនវែង សណ្ឋានជានេទួនតែស្រួចចុងដើមមានប្រវែងដល់ ៣០ ស-ម. ក៏មាន ។

២– ដំណើរ កំណើតគ្រុន – ពងវាចូលទៅក្នុងខ្លួនមនុស្សតាមបន្លែស្រស់ឬតាមទឹកឆៅ – ពងនោះញាស់ជាកូនទៅក្នុងពោះវៀន ។ លុះកូនធំឡើងវាពងបន្តជាប់ពងនោះធ្លាក់មកក្រៅតាមលាមក បើពងនេះទៅ

ប៉ះរបស់អ្វីដែលមនុស្សបរិភោគ ពងនោះនឹងញាស់ក្នុងពោះមនុស្សនោះ បន្តមកទៀត ។

៣ - ហេតុនាំឲ្យដឹងថាមានព្រូនក្នុងខ្លួន – ជួនកាលមានព្រូនចេញ តាមបាតឬតាមមាត់ - កាលណាព្រូនមានច្រើនក្នុងពោះ វាបណ្ដាលឲ្យពោះឲ្យប៉ុះភកឲ្យក្អួតឬឲ្យគ្រុន ។ បើកូនក្មេងវាបណ្ដាលឲ្យដេកចេះតែភ្ញាក់ កន្ត្រាក់ដៃជើង ជួនឲ្យប្រកាច់ជាស្កន់ជាន់ក៏មាន ។

៤ - កិច្ចការពារ .–

ក) អាស្រ័យតែទឹកដាំ តែបន្លែឆ្អិនឬស្រុសទឹកក្ដៅឲ្យស្អាត ។

ខ) កប់លាមក អ្នកជម្ងឺឆ្ងាយពីបឹងឬពីផ្លូវទឹក ។

គ) លាងដៃក្រោយពេលដែលបានប៉ះពាល់ប្រដាប់មនុស្សជម្ងឺប្រើ ។

អាទិត្យទី២– ដង្កូវនៅក្នុងពោះវៀន (ត) ព្រូនវែង គោលសេចក្ដី

ក) លក្ខណៈ ដង្កូវពងសំប៉ែត រស់នៅក្នុងពោះវៀនមនុស្សមាន ប្រវែងជួនដល់ ១០ឬ២០.ម. ខ្លួនវាមានថ្នាំងៗថ្នាំងធំៗនៅខាងកន្ទុយក្បាល តូចមានទំពក់សំរាប់តោងយ៉ាងស្អិត - វាច្រើនឆ្លងមកមនុស្សតាមសាច់ជ្រូក

ខ) ដំណើរកំណើតព្រូន - ថ្នាំងធំៗដែលពេញដោយពងដាច់ចេញ មួយម្ដងៗហើយចេញមកក្រៅតាមលាមក ។ ពងនេះចំរើនអាយុបានលុះ ណាតែបានចូលទៅក្នុងខ្លួនជ្រូក ឬ គោ ដែលវាទៅនៅតោងជាប់នឹងសាច់

សត្វនោះ ៗ កាលណាយើងស៊ីដោយសាច់សត្វនេះមិនឆ្អិនល្អ ព្រូននេះនឹងកើតក្នុងខ្លួនយើង ៗ

គ) ហេតុដែលនាំឲ្យដឹងថាមានព្រូននេះនៅក្នុងខ្លួន អ្នកមានព្រូនក្នុងខ្លួនបរិភោគច្រើនតែចេះតែស្គមជាលំដាប់ ៗ គេឃើញមានចំណែកខ្លួនព្រូនជាថ្នាំង ៗ នៅក្នុងលាមក ៗ

ឃ) កិច្ចការពារ – មានតែកិច្ចមួយយ៉ាងសំខាន់ គឺត្រូវបរិភោគតែសាច់ជ្រូកឬគោដែលគេបានចំអិនយ៉ាងឆ្អិនបំផុត ៗ

អាទិត្យទី ៣ ការអន្តរាយបណ្ដាលពីបារីនិងអាភៀន គោលសេចក្ដី

ថ្នាំមានជ័រដែលជាគ្រឿងពុល ៗ ជ័រនេះបណ្ដាលឲ្យខូចធ្មេញឲ្យចេញឈាមរត់ពុំស្រួល នឹងនាំឲ្យការដកដង្ហើមព្រមទាំងរំលាយអាហារដើរពុំបានស្រួលផង ៗ ការជក់បារីច្រើនហួស បណ្ដាលឲ្យខូចសុខភាព ៗ

ឯចំណែកអាភៀនមានជ័រខ្លាំងជាងថ្នាំទៅទៀត ៗ ក្រៅពីអន្តរាយធំដែលអាភៀនបណ្ដាលខាងផ្លូវចិត្ត អាភៀននាំឲ្យខូចគ្រឿងប្រដាប់ក្នុងខ្លួនមនុស្សជាច្រើន ៗ អ្នកជក់អាភៀនជាប់បរិភោគអ្វីក៏ពុំបាន ឡើងស្គាំងស្គកហើយចេះតែស្គមទៅ ៗ ព្រោះជ័រអាភៀនបំពុលឈាម ៗ គោង យើងបំបាត់ជំនឿមួយដែលថាអាភៀនជាឱសថសំរាប់កែរោគស្អួតបានយ៉ាង

ចំណាន  អាកេ ឧគ្រាន់តែឲ្យស្រោកផ្សំតែមួយកែ្តប៉ុណ្ណោះ បន្ទាប់ មកផ្សំរងើរតែតែទ្វេកម្លាំងឡើងទៀត ៗ

អាធិត្យទី៤. – អន្តរាយបណ្តាលពីស្រុក ៗ ទឹងរៀនសាដើម ៗ

---

បរិច្ចណាដ្ឋាន

## វត្ថុស្វាធ្យាយន៍

### អាធិត្យទី១.- អំពីអាកាស

វត្ថុសំពប់បង្រៀន ផ្តិតមួយទឹកមួយចានក្លាំ កែវទឹកមួយកូនជបមួយ ឲ្យសិស្សយកសៀវភៅឬផ្តិតមកបក់មុខវា មានអ្វីមកប៉ះមុខឯង? កាលណា ឯងរត់លេង ហេតុអ្វីបានជាកាវឯងហោង៉ធំឡើង? ឲ្យយកកែវទឹកទទេផ្កាប់ ហើយជ្រមុជទៅក្នុងចានក្លាំដែលមានទឹក, ទឹកចូលពេញកែវឬទេ? ហេតុអ្វី? ផ្សៀងកែវបន្តិចឃើញហេតុយ៉ាងណា? មានពពុះផុសចេញពីកែវ ហើយឡើងមកបែកលើទឹកពពុះនោះគឺអ្វី? បើដូច្នេះអាកាសមាននៅឯណាខ្លះ? គ្រប់កន្លែងសូម្បីតែប្រហោងតូចក៏មានអាកាសដែរ កាលណាយើង

ដកដង្ហើមយើងសំគាល់ក្លិនអាកាសដែលចេញចូលបានឬទេ? យើងមើលឃើញអាកាសគ្មានពណ៌គ្មានក្លិន ។

ប្រយោជន៍នៃអាកាសមនុស្សដែលលង់ទឹកដែលចង់ក ហេតុអ្វីបានជាស្លាប់? បើយកចាបមួយទៅគ្របឲ្យជិតកុំឲ្យអាកាសចូលបានបក្សីមុខជានឹងស្លាប់ បើដូច្នេះមនុស្សសត្វនឹងរុក្ខជាតិត្រូវការនឹងអាកាស អុចទៀនមួយឲ្យឆេះហើយយកបំពង់មួយគ្របឲ្យជិត ឯងឃើញហេតុយ៉ាងណា? ទៀនរលត់ពីព្រោះអ្វី? គ្មានអាកាសនឹងឲ្យឆេះ ដូច្នេះតែគ្មានអាកាស វត្ថុផ្សេងៗមិនអាចនឹងឆេះបានឡើយ ។

មេរៀនសង្ខេប.— អាកាសមាននៅគ្រប់តម្បន់ អាកាសគ្មានពណ៌គ្មានក្លិន អាកាសនឹងជួយទ្រទ្រង់ធាតុមនុស្សសត្វនឹងរុក្ខជាតិផងទាំងឡាយតែគ្មានអាកាសភ្លើងពុំអាចនឹងឆេះបានឡើយ ។

អាទិត្យទី២.— ១ អំពីទឹកនឹងភ្លៀង

២— អំពីពពក

វត្ថុសំរាប់បង្រៀន— ឆ្នាំងតូចមួយ កូនដើងក្រានមួយនឹងចានចាបមួយ មកធ្វើឲ្យសិស្សពិនិត្យហើយនឹងរកឲ្យឃើញហេតុ ។

## ការធ្វើឲ្យមើល

ដាក់ទឹកទៅក្នុងឆ្នាំងហើយដាំឲ្យពុះ លុះទឹកពុះបើកគ្របឡើង ៗ អ្វីដែលហុយពីឆ្នាំងឡើង ៗ ចំហាយទឹកហុយឡើងចំនួនទឹកក្នុងឆ្នាំងក៏ថយ ៗ យកចានទាបដាក់លើមាត់ឆ្នាំងចំហាយទឹកហុយទៅប៉ះ ហើយកកទៅជាដំណក់ទឹក ៗ វេលាដែលក្តៅ ទឹកទន្លេ. បឹង. សមុទ្រហួតឬទេ? ចំហាយទឹកដែលហួតបង្ករជាអ្វី ? ហេតុដូចម្តេចបានជាពពកអណ្តែត ហេតុដូចម្តេចបានជាទៅជាភ្លៀងបាន ៗ កាលណាពពកអណ្តែតទៅប៉ះទីងអាកាសត្រជាក់ ចំហាយទឹកនៅក្នុងពពកក៏កកទៅជាគ្រាប់ភ្លៀងធ្លាក់មកលើដី ដល់ភ្លៀងរួចទឹកភ្លៀងនោះហូរជ្រាបទៅក្នុងដីមួយប៉ែកទៀត ហូរដាក់ទៅក្នុងទន្លេធ្លាក់ទៅក្នុងសមុទ្រវិញដដែល ៗ ពពកខ្លះស ខ្លះជាផ្ទាំងខ្មៅ ជួនកាលមានរូបរាងចម្លែក ហើយមានពណ៌ផ្សេង ៗ តាមព្រះអាទិត្យ ពពកដែលបង្ករជាភ្លៀងធ្លាក់មកនោះគឺពពកខ្មៅតាមទីងដី ៗ

មេរៀនសង្ខេប.— ដោយចំហាយព្រះអាទិត្យទឹកក៏ហួតហើយកើតទៅជាចំហាយទឹក អណ្តែតផ្តុំគ្នាបានជាពពករសាត់តាមខ្យល់ពពកមានប្លែក ៗ ពីគ្នា តាមកំពស់តាមពេលវេលា កាលណាអណ្តែតទៅប៉ះលើអាកាសត្រជាក់ ពពកក៏កកទៅជាភ្លៀងចុះមក ៗ

## អាទិត្យទី ៣.– របៀបបែកពេលវេលាតាមបារាំងសែស

សុំគ្រូរកប្រក្រតីទិនបារាំងខ្មែរមកឲ្យសិស្សមើលថ្ងៃខែផងចុះ ។

របៀបបង្ហាញ– កំណត់ពេលវេលាគ្រប់មួយថ្ងៃ ពីអធ្រាត្រទៅទល់នឹងថ្ងៃត្រង់ហៅថាព្រឹក ពីថ្ងៃត្រង់ទៅទល់នឹងអធ្រាត្រហៅថាល្ងាច ។

ពេលនីមួយ ៗ មាន១២ម៉ោង មួយម៉ោងមាន៦០មីនុត មួយមីនុតមាន ៦០ វិនាទី (សឺកុង) ។

គ្រប់មួយឆ្នាំមាន ១២ ខែ ឲ្យរាប់លើប្រក្រតីទិន ខែនីមួយ ៗ មាន ៣០ឬ៣១ថ្ងៃ លើកតែខែហ្វេវ្រីយេរ៍ដែលមានតែ២៨ឬ២៩ថ្ងៃ គ្រប់មួយឆ្នាំមាន៣៦៥ឬ៣៦៦ថ្ងៃ ។

## អាទិត្យទី៤.– អំពីពេលវេលាតាមរបៀបខ្មែរ

ឲ្យរកមហាសង្ក្រាន្តខ្មែរមកបង្ហាញឲ្យបេះមើលថ្ងៃខែខ្មែរផង ។

របៀបខ្មែរ បែកថ្ងៃខែ មួយថ្ងៃមាន២៤ម៉ោង គឺព្រឹក១២ម៉ោង ល្ងាច១២ម៉ោង ខែបែកជាពីរចំណែក គឺខ្នើត១៥ថ្ងៃ រនោច១៤ឬ១៥ថ្ងៃ ថ្ងៃ១៥កើតគេហៅថាថ្ងៃពេញបូណ៌មី ពីព្រោះយប់ថ្ងៃនោះព្រះច័ន្ទពេញវង់ ថ្ងៃ១៤ឬ១៥រោចគឺខែដាច់ ដូច្នេះគ្រប់មួយខែខ្មែរមាន២៩ឬ៣០ថ្ងៃជាកំណត់ដរាប ។

គ្រប់មួយឆ្នាំមាន១២ខែឲ្យមើលលើមហាសង្ក្រាន្តខ្មែរ គឺខែមិគសិរ

បុស្ស- មាឃ- ផល្គុណ- ចេត្រ- ពិសាខ- ជេស្ឋ- អាសាឍ- ស្រាពណ៍ ភទ្របទ- អស្សុជនិងកត្តិកឲ្យរៀនសំគាល់លេខខែផង ជាការមានប្រយោជន៍ក្នុងសំបុត្រស្នាមដូចគេសរសេរថា ថ្ងៃ២៣១គឺជាថ្ងៃច័ន្ទ៣កើតខែមិគសិរ ។

---

បរិច្ឆណដ្ឋាន

## វិធីបង្ការរោគ

### អាទិត្យទី១ — អំពីមូស

មើលក្នុងសៀវភៅវិធីបង្ការរោគទំព័រលេខ៤១- ៤២- ៤៣- ៤៤

### អាទិត្យទី២ .— អំពីគ្រុនចាញ់

គ្រុនចាញ់ច្រើនមាននៅស្រុកណាដែលមាន ថ្លុកត្រពាំងបឹងបួរតំបន់ព្រៃ តំបន់ភ្នំនៅស្រុកក្តៅ ជម្ងឺនេះមានលក្ខណៈគ្រុនលោះឈឺក្បាល ដោយដៃជើងរាបណ្ដាលឲ្យស្លាប់ផង ជម្ងឺគ្រុនចាញ់បណ្ដាលអំពីមេរោគមួយយ៉ាងល្អិត ដែលមូសវានាំពីមនុស្សគ្រុន ចម្លងមកដល់មនុស្សជា ៗ

ដើម្បីនឹងជៀសវាងកុំឲ្យមូសខាំបាន ត្រូវដេកជាក់មុង ហើយបំផ្លាញដង្កូវទឹកដោយប្រេងកាតឬលែងត្រីឲ្យស៊ីឬដាំស្រូវ ។

បើឈឺគ្រុនចាញ់ត្រូវលេបឬចាក់គីនីនទើបបានជា ។

### អាទិត្យទី៣.– អំពីជម្ងឺពិស

សូមមើលក្នុងសៀវភៅវិធីបង្ការរោគទំព័រលេខ១៤៥ ។

---

## កុមារដ្ឋាន

## វត្ថុសាធ្យាយ

### អាទិត្យទី១.– អំពីផែនដី

មនុស្សយើងនឹងសត្វ ដើមឈើរស់នៅលើដីផ្ទៃដីស្មើរហូតឬមួយយ៉ាងណា ? មានកន្លែងខ្លះខ្ពស់កន្លែងខ្លះទាប នៅកន្លែងណាដែលផ្ទៃដីខ្ពស់ នៅកន្លែងភ្នំ ។ នៅកន្លែងណាដីទាប នៅមាត់ទន្លេមាត់សមុទ្រ ។

គេច្រើនដាំដំណាំនៅទីដីខ្ពស់ឬមួយនៅវាលទំនាប ។ ពេលណាភ្លៀងរួច ឯងសង្កេតឃើញអ្វីនៅកន្លែងទំនាប ទឹកភ្លៀងព្រោះ ជំនួលនាំយកអ្វីមកដាក់ទីទំនាប ។

អាទិត្យទី ២.— អំពីមេឃ

អាទិត្យទី៣.— អំពីផ្កាយ

អាទិត្យទី៤.— ព្រះអាទិត្យ

សូមមើលក្នុងសៀវភៅវិជ្ជាខេមរភាសាសម្រាប់ថ្នាក់បវរវិជ្ជដ្ឋាន ។

## វិធីបង្ការរោគ

សាបជ្រៀនពីដើមឡើងវិញ

## លោកនីតិ

សម្រាប់គ្រូបង្ហាត់

របៀបចាត់ចែងខាងហិរញ្ញវត្ថុក្នុងព្រះរាជអាណាចក្រកម្ពុជា ។

### មេរៀនទី១.— ថវិកាគាគា

ដែលហៅថាថវិកាគឺ ប្រាក់ចំណូលនិងចំណាយនៃរដ្ឋក្រុងខេត្ត ឃុំ ឬរបស់ឯកជនណាមួយ ។

នៅក្នុងវង្សត្រកូលនិមួយៗ ស្រីមេផ្ទះគត់មត់ល្អត្រូវដឹងធនធានដែលខ្លួនមាន ។ គេប្រុងប្រយ័ត្នក្នុងការចាយវាយដោយពៃលកមិនឲ្យចំណាយហើសលប់លើធនធានខ្លួនឡើយប្រព្រឹត្តបែបនេះហៅថារៀបចំថវិកាខ្លួន ។

ឯរដ្ឋក្រុងខេត្តឃុំ ក៏ធ្វើដូចស្ត្រីមេផ្ទះនេះដែរ ពល់ឆ្នាំគឺរៀបចំថវិកាដែលចែកជាពីរផ្នែក ៖ ចំណូលនិងចំណាយ ។

នៅប្រទេសកម្ពុជាមានថវិកាឃុំ ថវិកាខេត្ត ថវិកាក្រុងនិងថវិកាជាតិសំរាប់ប្រទេសទាំងមូល ។

ចំណូល.— ប្រាក់ចំណូលនៃថវិកាទាំងនេះ កើតឡើងពីផ្នែកច្រើន ៗ ផ្នែកចំណូលធំជាងគេ គឺ ផ្នែកខាងពន្ធនិងអាករ ។

ផ្នែកចំណូលដ៏សំខាន់កើតមកពី ៖

ក )— ផលនៃប្រាក់បន្ថែមភាគរយ ( ប្រាក់បន្ថែមភាគរយគឺចំនួនប្រាក់ដែលរាជការឲ្យហូតយកជាចំណូលនៃថវិកាឃុំខេត្តឬថវិកាក្រុង ):

ខ )— ផលនៃដែនរាជការ ( ផាស៊ីផ្សារ - ឈ្នួលដី ។ល ។

គ )— ផលនៃអាករឃុំឬអាករខេត្ត ;

ឃ )— ផលនៃការលក់ពិន័យផ្សេងៗ

ង )— ផលនៃការលក់ទ្រព្យសម្បត្តិរាជការ

ច )— ផលកើតអំពីទានឬអច្ច័យទានទាំងឡាយ

ឆ )— ជួនកាលថវិកាខេត្ត បានប្រាក់ជំនួយមកពីថវិកាជាតិហើយថវិកាឃុំបានប្រាក់ជំនួយមកពីថវិកាខេត្តដូច្នេះក៏មាន ។

ចំណាយ. ចំណូលទាំងឡាយនៃថវិកាផ្សេង ៗ នេះសំរាប់ចាយវាយសឹងមានមុខដូចរាយតទៅ ៖

ក)– ចំណាយសំរាប់ការប្រព្រឹត្តទៅនៃក្រសួងសាធារណៈផ្សេងៗ ហើយនិងចំណាយជាប្រយោជន៍ចំពោះប្រទេស ( ក្រុមរាជការប៉ូលិសគ្រឹស្ថានសិក្សាការថែទាំថ្នល់គ្រឹស្ថានរាជការក្រុមវិថីបាល )– ។

ខ) - ចំណាយសំរាប់សង្គមកិច្ច ( ជំនួយដលពល់រដ្ឋមានអាសន្ន អត់បាយទឹកលិចឬភ្លើងឆេះផ្ទះ ។ល។

មេរៀនទី២.–ថវិកាជាតិ-ប្រាក់ចំណូលខាងថវិកាជាតិបានមកអំពី ៖

ក)– ពន្ធចំពោះដូចជាពន្ធជួយជាតិ ដែលរាជការបំបាត់ចោល កាលពីឆ្នាំ១៩៤៩,ពន្ធដី, ប៉ាតង់ត៍,ពន្ធលើនេសាទុបករណ៍ ។ល។

ខ)– ពន្ធមិនចំពោះដូចជាពន្ធហូតលើការលក់ទំនិញដែលរាជការ កាន់ការផ្តាច់មុខ (អំបិលអាភៀន) ពន្ធឧបភោគបរិភោគអាករលើ ផលរបរ ។ល។

គ)– ពន្ធកន្ទៃងចាប់ត្រីអាករលើផលក្នុងប្រទេសដែលត្រូវដឹកនាំ ទៅប្រទេសក្រៅ ពន្ធខ្នងព្រៃ ។ល។

ឃ)– ចំនួនប្រាក់ខ្លះដែលថវិកាសមារដ្ឋបង្វិលជាជំនួយមកឲ្យ (Ristournes) ប្រាក់ចំណូលទាំងនេះសំរាប់ចាយវាយសឹងមានមុខដូចរាយតទៅ ៖

ក) - ចំណាយសំរាប់ការប្រព្រឹត្តទៅនៃក្រសួងសាធារណៈផ្សេងៗ តុលាការរដ្ឋសភាមន្ទីរស្តីការរដ្ឋមន្ត្រីក្រសួងជាតិផ្សេងៗ

ខ)- ជំនួយប្រាក់ដំពោះថវិកាក្រុងហើយនិងថវិកាខេត្ត ។

គ) – ចំណាយសំរាប់ធ្វើឲ្យប្រទេសបានចំរើនខាងសេដ្ឋកិច្ចការស្ថាបនាថ្នល់ទំនប់មជ្ឈមណ្ឌលនៃការស្វែងរកសេដ្ឋកិច្ច ការជីកព្រែកការបណ្ដុះពោធិ៍តាមថលមគ្គ ។ល។

ឃ) – ចំណាយសំរាប់កងទ័ព –

ង) – ចំណាយសំរាប់សង្គមកិច្ចផ្សេងៗការសិក្សានឹងអប់រំប្រជាជនការរំងាប់ជម្ងឺទាំងពួង ។ល។

អាករគយអាករប្រៃសនីយ៍ទូរលេខ ទូរសព្ទតម្លៃតែមប្រើនឹងចុះបញ្ជីការព្រមទាំងផលប្អាករអ្វីផ្សេងៗទៀត មិនបានជាចំណូលមកក្នុងថវិកាជាតិអាករទាំងអំបាលនេះចូលទៅខាងថវិកាសហរដ្ឋ ។ លុះនៅពេលដាច់ឆ្នាំម្ដងៗទើបប្រទេសខ្មែរទទួលពីថវិកាសហរដ្ឋនេះ នៅចំនួនប្រាក់មួយផ្នែកជាប្រាក់បង្វិលមក(Ristournes) ។

មេរៀនទី ៣.– ពន្ធចំពោះនិងពន្ធមិនចំពោះ

ពន្ធជាចំនួនប្រាក់មួយដែលមនុស្សជំពូកខ្លះបង់ជូនរាជការ ដើម្បីជាប្រាក់សំរាប់ចាយក្នុងការសាធារណៈ ។

ពន្ធមានពីរយ៉ាង ៖ ពន្ធចំពោះនិងពន្ធមិនចំពោះ

ពន្ធចំពោះគឺពន្ធចំពោះឈ្មោះមនុស្ស ។ រាជការរាយឈ្មោះមនុស្សជាប់ពន្ធទាំងនោះក្នុងបញ្ជីមួយ ដែលភ្នាក់ងាររាជការធ្វើទុកជាមុន ។

ក – មនុស្សបង់ពន្ធដើម្បីនឹងធ្វើជំនួញឬដើម្បីនឹងប្រព្រឹត្តទៅនូវការចិញ្ចឹមជីវិតផ្សេងៗ; ពន្ធដែលមនុស្សនោះបង់ហៅថាពន្ធចំពោះ ។

ពន្ធមិនចំពោះ គឺពន្ធដែលរាជការហូតយកមិនចំពោះពីឈ្មោះមនុស្សណាឡើយ ។

ខ -- កាលណាអ្នកទិញបារីមួយកញ្ចប់អ្នកចេញប្រាក់សំរាប់ថ្លៃបារីផងសំរាប់អាករពិសេសមួយយ៉ាងផង ។

អ្នកជៀសវាងមិនបង់អាករនេះបាន កាលណាអ្នកមិនជក់បារី ។ បើកាលណាអ្នកត្រូវការបារីអ្នកត្រូវតែបង់ ។

រាជការហូតពន្ធនេះមិនចំពោះពីឈ្មោះមនុស្សណាឡើយ គឺហូតយកចំពោះតែអំពីនៃមនុស្សទៅ ។

ពន្ធចំពោះសំខាន់ៗគឺៈ ពន្ធដី - អាករលើផលរយដម្លៃប៉ាតង់តពន្ធរទេះពន្ធសត្វ ។ល។

ពន្ធមិនចំពោះសំខាន់ៗគឺៈ ពន្ធទំនិញដែលដឹកចេញឬនាំចូល·អាករប្រៃសនីយ៍ទូរលេខ ទូរសព្ទ ដម្លៃតែមប្រើនឹងចុះបញ្ជីការ អាករលើឧបភោគបរិភោគ ( ពន្ធថ្នាំស្រា · ឈើគូស ។ល។ អាករលើផលរបរ ។ល។

មេរៀនទី ៤ — ការផ្តាច់មុខនិងការរត់គយ.

ការផ្តាច់មុខគឺជាសិទ្ធិបើកឲ្យជនឯកជនទិញដូរឬលក់ទំនិញអ្វីមួយផ្តាច់មុខតែម្នាក់ឯង ៗ ដូចជាជនឯទៀតដែរ រដ្ឋការទិញទំនិញទាំងពីរមុខនេះនៅក្នុងប្រទេសយើងឬពីប្រទេសក្រៅហើយ យកមកលក់ឲ្យជនអ្នកត្រូវការតាមថ្លៃដែលរដ្ឋការតម្រូវ ៗ រដ្ឋការអាចអនុញ្ញាតឲ្យមនុស្សខ្លះលក់ទំនិញជំពូកនេះជំនួសរដ្ឋការក៏បាន ៗ

ចំណែកខាងអំបិលរដ្ឋការបើកអំណាចឲ្យមនុស្សខ្លះធ្វើក្នុងស្រែអំបិលជាច្រើន តែអំបិលដែលធ្វើកើតឡើងទាំងអំបាលមាន ម្ចាស់ស្រែអំបិលទាំងអស់ត្រូវលក់ឲ្យតែរដ្ឋការ រួចទើបរដ្ឋការយកមកលក់ឲ្យអ្នកត្រូវការតទៅទៀត ៗ ការរត់គយគឺការនាំចូលឬលួចលាក់ទំនិញទាំងឡាយដែលរដ្ឋការកាន់ការផ្តាច់មុខ ៗ

គេទុកការនេះជាការរត់គយដែរ ជនណានាំចូលឬលក់ទំនិញអ្វីដែលរដ្ឋការហាម (ដូចជាកាំភ្លើង.គ្រាប់-រំសេវជាដើម) ឬទំនិញណាដែលជាប់ពន្ធគយ ៗ

ការនាំទំនិញខ្លះចេញទៅប្រទេសដទៃដោយលួចលាក់ជាការរត់គយដែរ អំពើអ្នករត់គយដែលប្រាថ្នាចង់ឲ្យទំនិញរួចផុតពីពន្ធគយ គឺជាអំពើទុច្ចរិតមួយ ៗ

តុលាការធ្វើទោសជាទម្ងន់ដល់មនុស្សរត់គយទាំងឡាយ ៗ

## មេសូត្រចាំមាត់

(សម្រាប់គ្រប់ថ្នាក់)

### ១- ត្រូវកោតខ្លាចចាស់ព្រឹទ្ធាចារ្យ

មានថ្ងៃមួយនោះ សិស្សច្រើនកុញ្ញកុះ នៅតៀមអាហារ នាំគ្នាអង្គុយ ពេញអស់ជើងម៉ា បរិភោគភោជនា ប្រញាប់ចូលរៀន ។ មានតាចាស់ព្រឹទ្ធ ដើរចូលទៅជិត រកជើងម៉ាគ្មាន សិស្សម្នាក់អាណិត ក៏ក្រោកចាកបាន ជូនទៅតាបាន អង្គុយស្រួលហើយ ។ គាត់ថាចៅតា អ្នករៀនសាលា ប្លែកណាស់ចៅអើយ គ្រូអ្នកប្រដៅ គាសសរសើរហើយ សិស្សទាំងឡាយអើយ ចូរយកតម្រាប់ ។

ពាក្យពន្យល់.– ព្រឹទ្ធាចារ្យ (ម.ប ព្រឹទ្ធ ឆាចា) អាចារ្យដែលមានអាយុច្រើន ។ ព្រឹទ្ធ =(ម.ប. ព្រឹទ្ធ) មានអាយុច្រើន ។ តៀម=ផ្ទះធ្វើផ្ទាល់នឹងផ្ទៃផែនដី សម្រាប់ដាក់ទំនិញលក់ដូរ ។

### ២- របៀបរៀនមេទន្ទេញឲ្យឆាប់ចាំស្ទាត់

បើរៀនរឿងអ្វី ចូរសិស្សប្រុសស្រី សង្កេតឲ្យជាក់ ហើយទើបទន្ទេញ កុំឲ្យរអាក់ ឃ្លាមួយចាំជាក់ មើលឃ្លាបន្ទាប់ ៗ តទៅ

ចូរថា ឃ្លាមុននោះណា ផល់ឃ្លាលំដាប់ បន្ទាប់ជាប់គ្នា ទើបអ្នកចាំឆាប់ ហើយចូរប្រញាប់ ទន្ទេញឲ្យចប់ ។ លុះចប់កាលណា ចូរអ្នកសូត្រសា ឲ្យច្រើនត្រឡប់ តែកុំមើលច្បាប់ ទើបចិត្តចាំស្កប់ ចាំបែបឲ្យគ្រប់ មេទន្ទេញហោង ។

ពាក្យពន្យល់.— រគាក់= (មកពីពាក្យរគាក់រអួល)

## ៣– ការត្រឡប់មកភូមិកំណើតវិញ

ខ្ញុំនៅកុមារ បានចរយាត្រា សិក្សានៅទី ក្រុងមួយជាបាន ព្រះរាជធានី ស្វែងរកអាជី- វប្បវត្តិមួយ ។ ការរៀនជីពជន្ម គាប់ចិត្តពេកពន់ ពុំដែលមានព្រួយ លុះយូរៗទៅ កើតមានចិត្តមួយ ភយមាយរំជួយ ទ្រាំនៅពុំបាន ។ ទើបខ្ញុំម្នីម្នា ត្រឡប់យាត្រា មកកាន់ភូមិឋាន មានចិត្តសោមនស្ស ដោយបានវិលប្កាន មកនៅ ភូមិឋាន ទីដែលខ្ញុំកើត ។

ពាក្យពន្យល់.— រាជធានី = នគរ, ក្រុងដែលព្រះរាជាគង់នៅ ។ អាជីវប្បវត្តិ = ដំណើរប្រព្រឹត្តទៅនៃជីវិត ។ ជីព = ជីវិត (ច្រើននិយាយថា ជីពជន្ម)

## ៤- ការសង្គ្រោះចំពោះបាវព្រាវ

បើមានបាវព្រាវប្រើ នៅបំរើគាប់ការប្រាក់
ឬមកសុំសំណាក់ នោះត្រូវអ្នកកាន់សុចរិត ៗ
កុំពោលពាក្យឡេះឡោះ ពោលចំពោះពាក្យដែលពិត
គ្នាធ្វើហួសគំនិត ត្រូវតាំងចិត្តមេត្តាផង ៗ
បើសិនបាវប្រុសស្រី ធ្វើការអ្វីត្រូវទំនង
រង្វាន់ឲ្យម្ដង ៗ ឈ្មោះថាចង់ឲ្យធ្វើការ ៗ
ហើយយកចិត្តទុកដាក់ បំរើអ្នកនឿយយ៉ាងណា
សរសើរហើយមេត្តា ខឹងសំបារត្រូវខំអត់ ៗ

ពាក្យពន្យល់.— ពោល = និយាយ, ស្ដី, ថា ៗ ពិត
មែន, ប្រាកដ ទៀង ៗ

## ៥- ត្រូវកាន់ចិត្តអំណត់

អ្នកប្រាជ្ញពោលទុកថា រីការខឹងយ៉ាងណាក្ដី
គ្រប់រូបមនុស្សប្រុសស្រី ខឹងនាំខុសពុំដែលត្រូវ ៗ
បាត់ខឹងដឹងខ្លួនខុស ធ្វើដូច្នោះស្ដាយក្រោយគួរ
ដូចថ្លែងពីឈ្មោះពៅ លំនៅគាត់ឃុំបែកបាន ៗ
ព្រឹកពៅចេញភ្ជួរស្រែ លុះតែថ្ងៃក្ដៅដល់ប្រាណ

កំគាត់ត្រឡប់ថ្កាន មើលបង្ក្រានឃើញប្រពន្ធ ៗ
កំពុងតែដាំបាយ ក្តៅក្រហាយព្រោះឃ្លានលន់
ដើរត្មះទៅប្រពន្ធ ថែមទាំងស្ទុះទៅទះប៉ុង ៗ
ត្រូវក្អកឈាមសស្រាក់ លុះហើមខ្វាក់ឈឺយ៉ាងខ្លាំង
រកថ្នាំបិនបារាំង រកទាំងគ្រូមើលពុំជា ៗ
ងងឹតងិតក្អកទៅ ទើបអ្នកនៅឃើញវេទនា
អាណិតដល់ភរិយា ស្តាយអាត្មាខឹងជ្រុលហោង ៗ

ពាក្យពន្យល់ ថ្កាន = សំដៅ, បំពោះទៅរក ៗ ត្មះ = តិះ
ដៀលឲ្យអាមាសមុខ ៗ អាត្មា = ខ្លួន ៗ

រោងពុម្ពខ្មែរ